# កម្ពុជាក្រោម

ព្រឹត្តិបត្របោះពុម្ពផ្សាយជារៀងរាល់ខែ ដោយសហព័ន្ធខ្មែរកម្ពុជាក្រោម

លេខ ១៦ ឆ្នាំទី ០២ - ខែមេសា គ.ស. ២០០៥ - ព.ស. ២៥៤៨ - N0 16, April, 2005


# លិខិតជូនពរឆ្នាំថ្មីរបស់លោក ចៅ រៀប

## ប្រធានសភាព្រឹទ្ធាចារ្យ សហព័ន្ធខ្មែរកម្ពុជាក្រោម

នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា សប្តស័ក ព.ស. ២៥៤៩ គ.ស. ២០០៥ លោក ចៅ រៀប ប្រធានសភាព្រឹទ្ធាចារ្យ សហព័ន្ធខ្មែរកម្ពុជាក្រោម បានធ្វើលិខិតជូនពរឆ្នាំថ្មី ប្រគេនព្រះ-តេជគុណ និងជូនជនរួមជាតិ ដែលមានអត្ថន័យសង្កត់ធ្ងន់ទៅលើស្មារតីរួបរួមជាតិជាធ្លុងមួយ ចាត់ទុករឿងជាតិជាសំខាន់ និងអំពីនយោបាយប្រជាតិថុតិរបស់យួនមកលើខ្មែរក្រោម ។



លោក ចៅ រៀប ប្រធានសភាព្រឹទ្ធាចារ្យសហព័ន្ធខ្មែរកម្ពុជាក្រោម

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !

សូមគោរពបងប្អូនរួមជាតិជាទីស្នេហា !

នាឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា សប្តស័ក ព.ស. ២៥៤៩ គ.ស. ២០០៥ ដែលកំពុងខិតជិតមកដល់ខាងមុខនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ ក្នុងនាមប្រធានសភាព្រឹទ្ធាចារ្យ សហព័ន្ធខ្មែរ-កម្ពុជាក្រោមពិភពលោក និងក្នុងនាមខ្ញុំបាទផ្ទាល់ សូមប្រសិទ្ធិពរជ័យសិរីមង្គល វិបុលសុខមហាប្រសើរ ចូរកើតមានដល់បងប្អូនជនរួមជាតិគ្រប់ពេលវេលា កុំបីអាក់ខានឡើយ ។

ជាពិសេស ក្នុងឆ្នាំថ្មីនេះ សូមឲ្យបងប្អូនមានចិត្តគំនិតថ្មី មានស្មារតីរួបរួមសាមគ្គីជាធ្លុងមួយ គ្មានការប្រកាន់បក្ខពួក ដោយចាត់ទុករឿងជាតិជាសំ-ខាន់ ។

បងប្អូនជនរួមជាតិ និងសមាជិក សមាជិកាសហព័ន្ធខ្មែរកម្ពុជាក្រោម ជាទីគោរពស្នេហា!

ដូចបងប្អូនបានជ្រាបស្រាប់ហើយថា សព្វថ្ងៃនេះ រដ្ឋអំណាចកុម្មុយនិស្តយួន កំពុងតែអនុវត្តផែនការបំបាត់ជាតិសាសន៍ខ្មែរតាមគ្រប់រូបភាព នៅតាមបណ្តាខេត្តខណ្ឌលើមាតុភូមិកម្ពុជាក្រោម ដែលមានទាំងធម៌ក្តៅ និង ធម៌ត្រជាក់ផង ។

*តាមរយៈធម៌ក្តៅ ៖*

កាលពីឆ្នាំ ១៩៧៨ យួនបានដេញខ្មែរចំនួនរាប់ម៉ឺនគ្រួសារ នៅខេត្តមាត់ជ្រូក ឲ្យចាកចេញពីភូមិស្រុក ទៅរស់នៅឯតំបន់ដាច់ស្រយាល ដែលដីសុទ្ធសឹងជាភក់ ល្បាប់ និងទឹកជូរ បណ្តាលឲ្យបងប្អូនខ្មែរទាំងនោះស្លាប់អស់ជាច្រើននាក់ ដោយសារខ្វះទឹកសាបប្រើប្រាស់ប្រចាំថ្ងៃ ។ មិនតែប៉ុណ្ណោះ ទ្រព្យសម្បត្តិទាំងឡាយ ក៏ត្រូវរលាយអស់ផងដែរ ។ ទន្ទឹមជាមួយគ្នានោះដែរ យួនម៉ើយលី, យួន

## មាតិការឿង


-លិខិតជូនពរឆ្នាំថ្មីរបស់លោក ចៅ រៀប........១
-វិចារណកថា ខ្ទីកាំបិតសម្លាប់មនុស្ស ..........៣
-លិខិតអបអរសាទរ....................................៤
-ព្រះមហាវរក្សត្រស្នើវៀតណាម ថៃ ឡាវ......៥
-អង្គការសហប្រជាជាតិ...............................៦
-ឧត្តមស្នងការនៃអង្គការសហប្រជាជាតិ........៧
-សមាជិក-សមាជិកា អង្គការយូអិនភីអូ........៧
-រឿងកំពប់តែអុង.........................................៨
-វេទិកាគំនិតជាតិ.......................................១២
-រឿងសុវណ្ណកុមារ.....................................១៣
-លិខិតគាំទ្រ............................................១៦



ទីស្នាក់ការ ៖ P.O. Box 0193, Pennsauken, NJ 08110-0193, USA, Tel: (856) 583-1503, email: kkfnewsletter@khmerkrom.net, http://www.khmerkrom.net

បាថាន់, យួនបាគួ និងយួនទ្រឿងសើង បានបង្កើតក្រុមខ្មែរតស៊ូក្លែងក្លាយ ហើយចាត់ខ្មែរដែលលក់ខ្លួនឲ្យធ្វើជា អ្នកដែដល់ដើរបំផុសបំផុល និងប្រើគ្រប់ល្បិចកលដើម្បីចោទប្រកាន់ និងចាប់បងប្អូនខ្មែរជាជនស្លូតត្រង់ដាក់គុក ។ បងប្អូនរួមជាតិ ដែលមានទឹកចិត្តស្នេហាជាតិហួសហេតុ ខ្វះការពិចារណា ត្រូវបានស្លាប់ជាច្រើននាក់ ក្នុងឧបាយកលដ៏ខ្មៅងងឹតនេះ ។

*តាមរយៈធម៌ត្រជាក់ ៖*

ដោយរដ្ឋកុម្មុយនិស្តយួន បង្កព្យុះភ្លៀងមកលើបងប្អូនខ្មែរក្រោមមិនបានសម្រេច គេបានផ្លាស់ប្តូរកិច្ចកលនយោបាយបែបថ្មីពីធម៌ក្តៅមកធម៌ត្រជាក់វិញម្តង ។ សព្វថ្ងៃនេះ យួនបានផ្លាស់ប្តូរឥរិយាបថ ធ្វើជាមានទឹកចិត្តស្រឡាញ់ខ្មែរក្រោម ជួយឧបត្ថម្ភគាំពារគ្រប់បែបយ៉ាង ក្នុងនោះមានដូចជា ៖

-សាងសង់ផ្ទះឲ្យគ្រួសារខ្មែរដែលក្រីក្រ និងឲ្យខ្ចីបុលប្រាក់

-សាងសង់សាលាឲ្យកូនខ្មែររៀន

-សាងសង់សាលាបាលីឲ្យព្រះសង្ឃខ្មែររៀន

-ដើរជូនពរឆ្នាំថ្មី តាមវត្តអារាមខ្មែរ និងទៅចូលរួមក្នុងពិធីបុណ្យប្រពៃណី-សាសនាខ្មែរ ទោះជាគេជាជនកុម្មុយនិស្ត ពុំមានសាសនាក៏ដោយ ។

សូមបញ្ជាក់ថា ការសាងសង់ផ្ទះ រដ្ឋអំណាចកុម្មុយនិស្តយួនធ្វើត្រឹមតែដំបូល និងសសរទេ សម្រាប់ផ្តល់ឲ្យគ្រួសារខ្មែរដែលគេបានធ្វើឲ្យក្រីក្រ ដល់ថ្នាក់លែងមានលទ្ធភាពសង់លំនៅដ្ឋានដោយខ្លួនឯងបានទៅហើយ ។ ឯផ្នែកសិក្សាទៀតសោត គេគ្រាន់តែយកឈ្មោះថាសាងសង់សាលារៀនសម្រាប់កូនខ្មែររៀន ដើម្បីបង្វែងដានប៉ុណ្ណោះ ប៉ុន្តែធាតុពិត ក្នុងសាលានេះ សិស្សភាគច្រើន សុទ្ធសឹងជាកូនកម្មាភិបាលបក្សកុម្មុយនិស្តយួន ។ ចំពោះផ្នែកសាសនា យួនបានរៀបចំយ៉ាងហ្មត់ចត់ណាស់ គឺដាក់គណៈសង្ឃយួនមានភារកិច្ចត្រួតពិនិត្យឃ្លាំមើលគណៈសង្ឃខ្មែរជានិច្ច ទោះបីគេទិញទឹកចិត្តព្រះសង្ឃខ្មែរបានដោយការផ្តល់បុណ្យសក្តិយ៉ាងណាក្តី ក៏គេនៅមិនទុកចិត្តទាំងស្រុងដែរ ។ គេពុំដែលអនុញ្ញាតឲ្យព្រះពុទ្ធសាសនាខ្មែរមានគណៈកម្មការកណ្តាលមួយឯកភាពដឹកនាំដូចសាសនាដទៃ នៅប្រទេសយៀកណាមឡើយ ។

បងប្អូនរួមជាតិជាទីគោរព !

ក្នុងកាលៈទេសៈនេះ សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោកប្រើប្រាស់ច្បាប់អន្តរជាតិ និងប្រកាន់យកធម៌អហិង្សាយ៉ាងខ្ជាប់ខ្ជួនស្របតាមមាគ៌ាព្រះពុទ្ធសាសនា ហើយមិនប្រកាន់ពូជសាសន៍ ឬពណ៌សម្បុរអ្វីឡើយ ។

ហេតុដូច្នេះ ក្នុងនាមខ្ញុំជាប្រធានសភាព្រឹទ្ធាចារ្យ សហព័ន្ធខ្មែរកម្ពុជាក្រោម និងតាងនាមលោកអធិបតី ព្រមទាំងសមាជិកសមាជិកាសហព័ន្ធខ្មែរកម្ពុជាក្រោម ខ្ញុំបាទសូមលើកហត្ថសារជាថ្មីម្តងទៀត សូមថ្វាយ និងជូនពរ សូមឲ្យសិរីមង្គលគ្រប់បែបយ៉ាងកើតមានដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងបងប្អូនជនរួមជាតិខ្មែរគ្រប់មជ្ឈដ្ឋាន ទាំងនៅក្រៅប្រទេស និងក្នុងប្រទេស ។

ខ្ញុំបាទមានកិត្តិយសរំឭកថា ជាតិសាសន៍ខ្មែរធ្លាប់មានអរិយធម៌រុងរឿង ល្បីល្បាញ ខ្លាំងពូកែ ដែលពុំមានជាតិសាសន៍ជិតខាងណាប្រៀបផ្ទឹមបានឡើយ ។ តែបច្ចុប្បន្ននេះ ផ្ទុយទៅវិញ ជាតិសាសន៍ខ្មែរបានធ្លាក់ចុះ ជិតដល់ចំណុចសូន្យដោយស្នាដៃរបស់យួនរហូតដល់បាត់សិទ្ធិធ្វើជាម្ចាស់ទឹកដីរបស់ខ្លួនទៀតផង ។

បងប្អូនរួមជាតិ ជាទីគោរព !

មិនតែប៉ុណ្ណោះ ភាសាជាតិក៏ត្រូវយួនបន្តការបំផ្លិចបំផ្លាញតាមរយៈដាក់កំហិតមិនឲ្យនាំចូលនូវឯកសារក្បួនខ្នាត ដែលសរសេរជាភាសាខ្មែរ ក្នុងខណៈពេលដែលឯកសារជាភាសាដទៃ ត្រូវបានគេនាំចូលកម្ពុជាក្រោមដោយសេរី ។ បើភាសារលត់ ជាតិក៏ត្រូវរលាយដែរ ព្រោះភាសាជាព្រលឹងជាតិ ដូច្នេះសូមបងប្អូនរួមជាតិពិចារណាអំពីតម្លៃនៃភាសា និងអក្សរសាស្ត្រជាតិ ហើយខិតខំថែរក្សាឲ្យបានគង់វង្ស ដើម្បីស្ថិរភាពជាតិខ្មែរ ។ យួនបានប្រើគ្រប់កលល្បិច ដើម្បីបំផ្លាញព្រលឹងជាតិខ្មែរ បំបាត់ពូជសាសន៍ខ្មែរនៅលើមាតុភូមិរបស់ខ្លួន ។ សូមបងប្អូនរួមជាតិខ្មែរ កុំយល់សប្តិថា យួនល្អនឹងខ្មែរនោះវាមិនអាចទៅរួចទេ ល្គឹកណាគេនៅមិនទាន់ទទួលស្គាល់ភស្តុតាងប្រវត្តិសាស្ត្រដែលបានចារយ៉ាងច្បាស់ពីអំពើឃោរឃៅ ព្រៃផ្សៃទាំងអម្បាលមាណមកលើខ្មែរកម្ពុជាក្រោម ហើយសុំទោសខ្មែរ ។ ដូចជាករណីធ្វើគុតព្រះតេជគុណ ឡឹម ខេន នៅវត្តទឹកល្អក់ ខេត្តព្រៃកប្បាស្សី កាលពីឆ្នាំ ២០០២ ថ្មី ៗ នេះ ជាអំពើដ៏ព្រៃផ្សៃជាទីបំផុត ដែលសហព័ន្ធខ្មែរកម្ពុជាក្រោមបានវែកមុខលើឆាកអន្តរជាតិ ហើយយួនក៏គ្មានអ្វីបដិសេធដែរ ។ ដូច្នោះហើយ មានតែខ្មែរទេ ដែលមានចិត្តអាណិតស្រឡាញ់ខ្មែរដូចគ្នា ព្រោះមានឈាមជ័រ និងពូជអំបូរតែមួយ ។

ជាចុងបញ្ចប់ សូមបងប្អូនជនរួមជាតិ និងសហសេវិក ក្នុងសហព័ន្ធខ្មែរកម្ពុជាក្រោម មេត្តារំឭកឡើងវិញ នូវប្រវត្តិដ៏ជូរចត់រវាងខ្មែរនិងយួន ក្នុងអតីត ក៏ដូចជាបច្ចុប្បន្ន ។ ហើយរក្សាឧត្តមគតិស្នេហាជាតិ ប្តេជ្ញាចិត្ត ហ៊ានបូជាទាំងកម្លាំងកាយចិត្ត និងមានសកម្មភាពជាក់ស្តែងដើម្បីសហព័ន្ធខ្មែរកម្ពុជាក្រោម ។

សូមទេវតាឆ្នាំថ្មី ព្រះនាងកិរិណីទេវី មេត្តាថែរក្សា និងប្រទានពរជ័យជូនជនរួមជាតិខ្មែរ និងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ ដែលកំពុងរងទុក្ខវេទនាក្រោមនឹមដែកអម្រែកថ្ម នៃអាណានិគមយួន ជួបប្រទះតែសេចក្តីសុខចម្រើនក្នុងឆ្នាំថ្មីនេះ ។

*"សាមគ្គីគឺរស់ បែកបាក់សាមគ្គីគឺស្លាប់"*

**សូមអរព្រះគុណ និងសូមអរគុណ !**

និពន្ធនាយក ៖ **ថាច់ ប៉ុកថាច់** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, សឺន ច័ន្ទ**
ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

## ល្បិចកលមួយ ក្នុងគម្ពីរបូរាណចិន ៖

# ខ្ចីកាំបិតសម្លាប់មនុស្ស

យួនជានិច្ចកាល តែងតែចាត់ទុកខ្មែរយើងជាសម្រាមក្នុងកែវភ្នែករបស់គេ រហូតមកទល់នឹងបច្ចុប្បន្ននេះ យើងពុំទាន់ឃើញយួនផ្លាស់ប្តូរឥរិយាបថដ៏ពិសពុលបន្តត្រកូលនេះបន្តិចណាឡើយ ។ ផ្ទុយទៅវិញឃើញកាន់តែពិសពុលខ្លាំងឡើង ៗ និងអនុវត្តដោយចំហនូវរាល់ផែនការបំបាត់ជាតិសាសន៍ខ្មែរទៀតផង គ្រាន់តែផ្លាស់ប្តូររូបភាពបន្តិចបន្តួចទៅតាមកាលៈទេសៈប៉ុណ្ណោះ ។ នៅពេលដែលគេគ្មានមធ្យោបាយ ឬក៏ត្រូវទទួលគំនាបពីសហគមន៍អន្តរជាតិស្រឡាញ់យុត្តិធម៌ ដែលមិនអនុញ្ញាតឲ្យយួនអនុវត្តផែនការប្រល័យពូជសាសន៍ខ្មែរដោយផ្ទាល់ដៃ គេនៅតែខិតខំធ្វើដោយប្រយោល ដូចជាខ្ចីដៃបងប្អូនខ្មែរនៅក្នុងស្រុក ដែលកំពុងលង់លក់នូវមនោគមវិជ្ជា បុណ្យ-ស័ក្តិ ឬ ទ្រព្យសម្បត្តិ ឲ្យវាយប្រហារខ្មែរគ្នាឯងនៅក្រៅស្រុក ក្នុងគោលបំណងបំបែកបំបាក់ ធ្វើឲ្យអន្តរាយដល់សង្គមខ្មែរដោយសារខ្មែរ ។

ជាក់ស្តែងក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ខណៈពេលដែលយួនកុម្មុយនិស្តចាប់ដៃយ៉ាងស្អិតរមួតជាមួយយួនសេរីមួយក្រុម ដែលមានលោក ង្វៀង កៅ គី ជាតំណាង គេបានតាក់តែងឯកសារមួយបង្គាប់បញ្ជាខ្មែរដែលកំពុងបម្រើការក្នុងជួររដ្ឋាភិបាលយួន និងមន្ត្រីសង្ឃខ្មែរនៅកម្ពុជាក្រោម ឲ្យហៅខ្មែរអ្នកស្នេហាជាតិនៅបរទេសថាជា "ខ្មាំង" ជា "ពួកប្រតិកិរិយា" ។ ថ្វីត្បិតតែជានិច្ចកាល ពេលនិយាយដល់ខ្មែរនៅបរទេស ឬថ្នាក់ដឹកនាំសង្គមស៊ីវិលខ្មែរដែលមានឧត្តមគតិគិតគូដល់ប្រយោជន៍ខ្មែរ យួនតែងតែប្រើពាក្យអសុជីវធម៌ ប្រាសចាកក្រមសីលធម៌ដើម្បីហៅដូចជា "ពួកអាខ្មាំងខ្មែរ" ឬ "ពួកអាថូ" ជាដើម ។ ប៉ុន្តែថ្មី ៗ នេះ មានរឿងចំឡែកមួយទៀត គឺគេបង្គាប់កម្មាភិបាល និងមន្ត្រីសង្ឃខ្មែរនៅក្នុងស្រុក ឲ្យប្រើប្រាស់សម្តីអសុរសទាំងនោះ ព្រោះបើគេហៅតែឯកឯង ហាក់បីដូចជាពុំមានប្រសិទ្ធភាព ឬក៏ខ្លាចសហគមន៍អន្តរជាតិចោទថាប្រកាន់ពូជសាសន៍ ? ឯកសារដែលជា "មេរៀន" នោះ រៀបរៀងដោយគណកម្មការបញ្ជាការតំបន់នីរតី (Ban Chi dao Khu Tay Nam bo) ត្រូវបានប្រជាពលរដ្ឋខ្មែរក្រោមនៅព្រះរាជាណាចក្រកម្ពុជាចាប់បាន និងចុះផ្សាយតាមរយៈសារព័ត៌មានក្នុងស្រុក កាលពីចុងឆ្នាំ ២០០៣ ។

ល្បិចកលខ្ចីកាំបិតសម្លាប់មនុស្ស ត្រូវបានអនុវត្តដោយចំហដែលមានមនោគមវិជ្ជាជាឧបករណ៍ គេបង្រៀនឲ្យខ្មែរនៅក្នុងស្រុកហៅខ្មែរនៅក្រៅស្រុកថា "ខ្មាំង " ឬ "ពួកប្រតិកិរិយា" ។ ក្រៅពីនេះ គេបន្តការបំភិតបំភ័យកម្មាភិបាលខ្មែរកុម្មុយនិស្ត មិនឲ្យទាក់ទងជាមួយពិភពលោកខាងក្រៅ ដោយយកហេតុផលថា "ប៉ះពាល់នយោ-បាយ" ប៉ុន្តែគេពុំបានពន្យល់លំអិតអំពីការប៉ះពាល់នោះថាជាយ៉ាងណាឡើយ ។ ឬមួយគេគិតថាខ្មែរដែលធ្វើកុម្មុយនិស្តបម្រើគេនោះ ពុំមានវិចារញ្ញាណឬ ?

ចំណែកយួនកុម្មុយនិស្ត និងយួនសេរីវិញ គេកំពុងទុកមនោគមវិជ្ជាមួយកន្លែងសិន ដើម្បីជម្រុញសកម្មភាពបង្រួបបង្រួម និងផ្សះផ្សាជាតិ ហើយនិន្នាការនេះយើងអាចមើលឃើញ និងវាស់វាល់បានជាបរិមាណ តាមរយៈដំណើរមាតុភូមិនិវត្តលើកដំបូងរបស់លោក ង្វៀង កៅ គី នាឱកាសបុណ្យចូលឆ្នាំយួនក្នុងឆ្នាំ ២០០៤ លោកបានស្នើឲ្យអាជ្ញាធរកុម្មុយនិស្តយួន ឲ្យជួសជុលឡើងវិញនូវវិមានសពយុទ្ធជនយួនសេរីនៅខាងកើតព្រៃនគរ ដើម្បីសម្តែងនូវសុឆន្ទៈជាសក្ខីភាព របស់ភាគីយួនកុម្មុយនិស្ត ចំពោះយួនសេរីដែលគាំទ្រលោក គី ។

ទោះបីជាការបង្រួបបង្រួមភាគីយួនទាំង ២ នៅមានការលំបាកយ៉ាងណាក៏ដោយ ព្រោះថា លោក ង្វៀង កៅ គី ពុំមែនជាតំណាងឆន្ទៈរបស់យួនសេរីទូទៅនៅបរទេសទេ ពោលគឺ នៅមានយួនសេរីជាច្រើនក្រុមទៀត ដែលប្រឆាំងជំទាស់ជាមួយលោក គី ប៉ុន្តែយ៉ាងណាក៏ដោយ ការជួសជុលវិមានសពយុទ្ធជនយួនសេរីនៅខាងកើតព្រៃនគរជាវត្ថុបញ្ចាំចិត្ត និងសឲ្យឃើញថាអាជ្ញាធរយួនកុម្មុយនិស្តបានបោះបង់បញ្ហាមនោគមវិជ្ជាចោលហើយ ប្រសិនបើមានការលើកឡើងអំពី កុម្មុយនិស្ត-សេរី ទៀតនោះ គឺគ្រាន់តែដើម្បីបោកបញ្ឆោតខ្មែរកុម្មុយនិស្ត និង ខ្ចីដៃខ្មែរកុម្មុយនិស្ត វាយប្រហារមកលើជនរួមជាតិខ្មែរនៅបរទេសប៉ុណ្ណោះ ៕

VOKK

# លិខិតអបអរសាទររបស់លោក ថាច់ ង៉ុកថាច់

## ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម ផ្ញើជូនលោក ចច ដឺបល្យូប៊ូស ក្នុងឱកាសលោកឡើងកាន់តំណែងជាប្រធានាធិបតីសហរដ្ឋអាមេរិកសាជាថ្មី ។



*លោក ចច ដឺបល្យូប៊ូស ប្រធានាធិបតីសហរដ្ឋអាមេរិក*

លោកប្រធានាធិបតីជាទីគោរព !

ក្នុងឱកាសដ៏ថ្លៃថ្លាជាប្រវត្តិសាស្រ្ត នៃទិវាឡើងកាន់តំណែងប្រធានាធិបតីសហរដ្ឋអាមេរិកសាជាថ្មីរបស់លោក ក្នុងអាណត្តិទីពីរនេះ ខ្ញុំបាទតាងនាមឲ្យប្រជាជាតិខ្មែរកម្ពុជាក្រោមរាប់លាននាក់ សូមចូលរួមអបអរសាទរក្នុងទិវាដ៏មហោឡារិកនេះ និង សូមប្រសិទ្ធិពរឲ្យតំណែងប្រធានាធិបតី ក្នុងអាណត្តិទីពីររបស់លោក ប្រកបដោយជោគជ័យជាភិយ្យោភាព ។

ក្នុងអាណត្តិ ៤ ឆ្នាំនៃតំណែងប្រធានាធិបតីអាមេរិករបស់លោកកន្លងមក បានជួបប្រទះនូវចលាចលផ្សេង ៗ ដែលបង្កឡើងដោយពួកភេរវជន តែដោយស្ថិតនៅក្រោមការដឹកនាំដ៏អង់អាចក្លាហាន វាងវៃរបស់លោក ដើម្បីបុព្វហេតុសិទ្ធិសេរីភាព និងលទ្ធិប្រជាធិបតេយ្យសម្រាប់មនុស្សជាតិលើពិភពលោក ចលាចលទាំងនោះ ត្រូវបានវិនាសទៅវិញគួរជាទីមោទនៈ ។ ជាសក្ខីភាពប្រជាពលរដ្ឋ នៅក្នុងប្រទេសអាហ្វហ្កានីស្ថាន ក៏ដូចជាប្រជាពលរដ្ឋនៅក្នុងប្រទេសអៀរ៉ាក់ ពួកគេកំពុងតែទទួលបាននូវសិទ្ធិសេរីភាព ដែលជាសេចក្តីប្រាថ្នារបស់ពួកគេនោះហើយ ។

តែជាអកុសល ក្នុងអំឡុងពេលនេះដែរ នៅក្នុងតំបន់មួយចំនួន រដ្ឋាភិបាលនៅតែប្រកាន់យកអំពើហិង្សា ប្រើលិទ្ធិផ្តាច់ការ កេងយកផលចំណេញពីសង្គ្រាមបង្ក្រាបពួកភេរវកម្មរបស់អាមេរិក ធ្វើជាលេសមកសង្កត់សង្កិនលើប្រជាពលរដ្ឋរបស់ខ្លួន ជាពិសេសគាបសង្កត់មកលើជនជាតិភាគតិច ជនជាតិដើមទៅវិញ ។ តួយ៉ាងដូចជារដ្ឋាភិបាលកុម្មុយនិស្តយួនសព្វថ្ងៃ កំពុងតែគាបសង្កត់ និងបំបិទសិទ្ធិសេរីភាពរបស់ជនជាតិដើមខ្មែរកម្ពុជាក្រោម និងពួកកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ា ជាដើម ។

លោកប្រធានាធិបតីជាទីគោរព ! ប្រជាជនខ្មែរកម្ពុជាក្រោមជាច្រើននាក់ បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពសម្ព័ន្ធមិត្តរបស់អាមេរិកាំង តស៊ូប្រយុទ្ធយ៉ាងអង់អាច ក្លាហាន នាសម័យសង្គ្រាមនៅវៀតណាម ។ ហើយសព្វថ្ងៃពួកគេកំពុងតែទទួលរងនូវការជិះជាន់ធ្វើទុក្ខបុកម្នេញឥតឈប់ឈរ ពីសំណាក់របបយួនកុម្មុយនិស្តផ្តាច់ការតាំងពីខែមេសា ឆ្នាំ ១៩៧៥ រហូតមក ។

ដូច្នេះ យើងខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំទៅលើរដ្ឋាភិបាលក្នុងអាណត្តិទីពីររបស់លោក ក្នុងការពង្រីកលទ្ធិប្រជាធិបតេយ្យ និងលើកស្ទួយសិទ្ធិសេរីភាពនៃមនុស្សជាតិនៅលើពិភពលោក ក៏ដូចជាជួយរំដោះប្រជាជាតិខ្មែរកម្ពុជាក្រោម និង ជនជាតិភាគតិចដទៃទៀតចេញពីនឹមដែកអាណានិគមយួន ឲ្យមានសិទ្ធិសេរីភាពពេញលេញដោយបញ្ចប់ទាំងស្រុងនូវរបបអាណានិគមនៅលើទឹកដីកម្ពុជាក្រោម។

ជាថ្មីម្តងទៀត តាងនាមឲ្យប្រជាជាតិខ្មែរកម្ពុជាក្រោម សូមប្រសិទ្ធិពរជ័យជូនលោកប្រធានាធិបតី ឲ្យជួបប្រទះតែសេចក្តីសុខ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់លោក ក្នុងការពង្រីកលទ្ធិប្រជាធិបតេយ្យ និងជួយមនុស្សជាតិលើពិភពលោកទទួលបាននូវសិទ្ធិសេរីភាពពេញលេញ បញ្ចប់របបអាណានិគមនៅលើពិភពលោក ។

សូមលោកប្រធានាធិបតី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ !

**ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម**
**ថាច់ ង៉ុកថាច់**

# ព្រះមហាវីរក្សត្រស្នើវៀតណាម ថៃ ឡាវ ប្រគល់ទឹកដី សមុទ្រ កោះ ដែលគេលួចយក មកឲ្យកម្ពុជាវិញ

ភ្នំពេញ ៖ ព្រះមហាវីរក្សត្រ ព្រះបាទ សម្ដេច ព្រះនរោត្តម សីហនុ កាលពីថ្ងៃទី ៣១ ខែមីនា បានផ្ញើលិខិតចំហដ៏កម្រមួយទៅកាន់រដ្ឋសភា និងរដ្ឋាភិបាលប្រទេសថៃ វៀតណាម និងឡាវ ដើម្បីស្នើឲ្យប្រទេសទាំងបីនេះ ប្រគល់មកឲ្យប្រទេសកម្ពុជាវិញនូវ ទឹកដី សមុទ្រ និងកោះរបស់កម្ពុជា ដែលព្រះអង្គបានអះអាងថាពួកគេបានលួចយកទៅគ្រប់គ្រង ។

ព្រះមហាវីរក្សត្រ ព្រះជន្ម ៨២ ព្រះវស្សា បានទ្រង់លិខិតជាភាសាបារាំងនូវលិខិតចំហ ដែលមានខ្លឹមសារបកប្រែក្រៅផ្លូវការដូចខាងក្រោម ។

I–នៅក្នុងសម័យកាលក្រោយសម័យអង្គរ (សតវត្សរ៍ទី១៥ រហូតដល់ទី ១៩ និងក្រោយមកទៀត) ប្រទេសថៃ (សៀម) និងប្រទេសវៀតណាម (អាណ្ណាម) ជាពិសេសបានធ្វើសង្គ្រាមឈ្លានពាន និងវាតទីទឹកដីប្រឆាំងប្រទេសកម្ពុជា ។ ជាលទ្ធផលដែលពិភពលោកទាំងមូលបានដឹង និងដែលត្រូវបានកត់ត្រាទុកនៅក្នុងប្រវត្តិសាស្ត្រសកលលោកនោះ គឺចក្រភពកម្ពុជាបានបាត់បង់ទឹកដី សមុទ្រ និងកោះមួយផ្នែកធំរបស់ខ្លួនយ៉ាងពិតប្រាកដ ។

ដោយសារតែភាពស្លូតបូត និងការស្រឡាញ់ គោរពឧត្តមគតិសន្តិភាព (ប្រជាជនខ្មែរមិនដែលខ្លាចចុះញ៉មក្នុងការធ្វើសង្គ្រាមជាមួយអ្នកឡើយ) កម្ពុជាមិនបានទាមទារឲ្យអ្នកប្រគល់មកឲ្យកម្ពុជាវិញនូវខេត្ត–ក្រុងទឹកដី សមុទ្រ កោះខ្មែរ ដែលត្រូវបានពួកអ្នករាល់គ្នាលេបត្របាក់នៅចន្លោះសតវត្សរ៍ទី ១៥ និងទី ១៩ ។

ប៉ុន្តែប្រជាជាតិ ប្រជាជនរដ្ឋកម្ពុជានឹងមិនអាចទទួលយកការបាត់បង់ (យ៉ាងអយុត្តិធម៌ និងខុសច្បាប់) សូម្បីតែមួយម៉ែត្រមួយដេស៊ីម៉ែត្រ មួយសង់ទីម៉ែត្រក្រឡានៃបូរណភាពទឹកដី (ដីគោក និងសមុទ្រ) ដែលជាកម្មសិទ្ធិស្របច្បាប់ដូចនៅក្នុងផែនទីអាមេរិក (មិត្តរបស់អ្នក និងជាអតីតសត្រូវរបស់នរោត្តមសីហនុ) ដែលបានគូសបញ្ជាក់យ៉ាងច្បាស់ ផែនទីនោះគឺជាផែនទីភូមិសាស្ត្រដែលត្រូវបានធ្វើឡើងនៅចន្លោះឆ្នាំ ១៩៦៣ (មួយឆ្នាំបន្ទាប់ពីតុលាការអន្តរ–ជាតិក្រុងឡាអេចេញ សាលក្រមប្រគល់ប្រាសាទព្រះវិហារមកឲ្យកម្ពុជា) និងឆ្នាំ ១៩៦៩ (មួយឆ្នាំមុនពេលរដ្ឋប្រហារខុសរដ្ឋធម្មនុញ្ញរបស់លន់ណុល, សិរីមតៈ និងបរិវាររបស់ចក្រពត្តិអាមេរិកាំង ប្រធានាធិបតី និក សុន) ។

II– ចាប់តាំងពីខ្ញុំវិលត្រឡប់ មកកាន់មាតុភូមិវិញនៅឆ្នាំ ១៩៩១ រហូតមកទល់បច្ចុប្បន្ននេះ ខ្ញុំកត់សម្គាល់ឃើញថា អ្នកទាំងបី (ថៃ វៀតណាម និងឡាវ) មិនបានឈប់ មិនឈប់ហើយបន្តទន្ទ្រានបន្តិចម្ដង ៗ ចូលក្នុងភូមិទឹកដីសមុទ្រ និងកោះរបស់កម្ពុជា ដែលជាសមាជិកអាស៊ានដូចអ្នកឯងរាល់គ្នាដែរ ។

ដោយគ្រាន់តែនិយាយអំពីភូមិរបស់ប្រជាជនខ្មែរ នៅជិតប្រទេសវៀតណាម ភូមិទាំងនេះជាច្រើនដែលនៅសម័យសង្គមរាស្ត្រនិមយ (១៩៥៥–១៩៦៩) បានស្ថិតនៅក្នុងប្រទេសកម្ពុជា ឥឡូវបែរជាស្ថិតនៅក្នុងទឹកដីសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយត្រូវបានយាមកាមនិងការពារបានយ៉ាងល្អដោយកងជីវពល និងយោធារបស់សាធារណរដ្ឋសង្គមនិយមវៀតណាមនេះ ។ ចំណែកឯពិភពលោកទាំងមូលបាននិយាយថា ខ្សែបន្ទាត់ព្រំដែនថ្មីនៃព្រំដែនសមុទ្ររវាងកម្ពុជា និងថៃ ព្រមទាំងរវាងកម្ពុជា និងវៀតណាមផ្តល់ចំណេញច្រើនដល់សមុទ្រ និងកោះប្រទេសជិតខាងទាំងពីរនេះ បើប្រៀបធៀបទៅនឹងសមុទ្រកោះ ដែលពួកគេមានរហូតមកត្រឹមឆ្នាំ ១៩៦៩ ។

III–ប្រជាជនកម្ពុជាទាំងប្រុសស្រី មិនថានៅក្នុង ឬ ក្រៅប្រទេសទេ ដែលមិនក្បត់មាតុភូមិរបស់ខ្លួន សូមទាមទារឲ្យអ្នកត្រូវតែគោរពដោយភាពថ្លៃថ្នូរចំពោះច្បាប់អន្តរជាតិ អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ កិច្ចព្រមព្រៀងបារាំងប៉ារីសឆ្នាំ ១៩៩១ ស្តីពីកម្ពុជាធម្មនុញ្ញសហប្រជាជាតិ ដោយទទួលយល់ព្រមប្រគល់ឲ្យកម្ពុជាវិញនូវភូមិ ទឹកដី សមុទ្រ កោះ ដែលអ្នកបានលេបត្របាក់ ឬក៏ចាប់យក ។

ព្រោះថា អ្នកបានអះអាងគ្រប់កន្លែងថា អ្នកមិនមែនជាចោរ ឬក៏អ្នកលេបត្របាក់យកភូមិ ទឹកដី សមុទ្រ និងកោះខ្មែរទេនោះ ដូច្នេះសូមអ្នកទទួលដោយសុទ្ធចិត្ត និងយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាននូវសំណើរបស់ខ្ញុំ ដែលចង់ឲ្យមានផ្ទៀងផ្ទាត់មួយគីឡូម៉ែត្រម្តង ៗ ទៅដល់កន្លែងតែម្តងចំពោះគំនូសបន្ទាត់ព្រំដែនរួមរបស់យើង (គំនូសបន្ទាត់ព្រំដែនស្ថិតនៅលើផែនទីភូមិសាស្ត្រអាមេរិក ដែលធ្វើឡើងដោយក្រុងវ៉ាស៊ីនតោនឌីស៊ី នៅចន្លោះឆ្នាំ ១៩៦៣ និង ១៩៦៩) ដោយភ្នាក់ងារពេញសមត្ថកិច្ចរបស់អ្នក និងដោយភ្នាក់ងារពេញសម–ត្ថកិច្ចរបស់កម្ពុជា ដែលតំណាងជាន់ខ្ពស់មួយរូប ៗ មកពីគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សសមរង្ស៊ី និងឯកឧត្តម ស៊ានប៉េងសែ ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ៕

*អត្ថបទដកស្រង់ពីសារព័ត៌មានរស្មីកម្ពុជាលេខ ៣៦៩១*

*ថ្ងៃសុក្រ ទី ០១ ខែមេសា ឆ្នាំ ២០០៥*

# អង្គការសហប្រជាជាតិចេញសេចក្ដីថ្លែងការណ៍ អំពីស្ថានភាពប្រជាពលរដ្ឋខ្មែរក្រោម

ក្រុមប្រឹក្សាកិច្ចការសេដ្ឋកិច្ច និង សង្គមរបស់អង្គការសហប្រជាជាតិ កាលពីថ្ងៃទី ១០ ខែមីនា កន្លងទៅនេះបានចេញសេចក្ដីថ្លែងការណ៍ នៃកិច្ចប្រជុំក្រុមប្រឹក្សាលើកទី ៦១ ប្រវែង ៥ ទំព័រ លើចំណុចចំនួន ១៩ ដែលជាសេចក្ដីថ្លែងដើមទាំងស្រុងរបស់វេទិកាប្រទេសក្នុងទ្វីបអាស៊ី អំពីស្ថានភាពប្រជាពលរដ្ឋខ្មែរក្រោមក្នុងអំណាចនៃប្រទេសយៀកណាម ។

សូមបញ្ជាក់ជូនថា វេទិកាប្រទេសក្នុងទ្វីបអាស៊ី ហៅថា (Forum-Asia) ទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ បានចេញសេចក្ដីថ្លែងខាងលើ ហើយដែលត្រូវបានយកទៅថ្លែងដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិនោះ គឺធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយអង្គការប្រជាពលរដ្ឋ និងជនជាតិដែលគ្មានតំណាងហៅកាត់ថា UNPO និងសហព័ន្ធខ្មែរកម្ពុជាក្រោម ។

សេចក្ដីថ្លែងការណ៍នោះ ទាមទារឲ្យកិច្ចប្រជុំលើកទី ៦១ នៃស្នងការសហប្រជាជាតិទទួលបន្ទុកបញ្ហាសិទ្ធិមនុស្ស យកចិត្តទុកដាក់លើការរំលោភសិទ្ធិមនុស្ស ដែលគេកំពុងប្រព្រឹត្តទៅលើពលរដ្ឋខ្មែរក្រោម នៅប្រទេសយៀកណាមបច្ចុប្បន្ននេះ ។

សេចក្ដីថ្លែងឲ្យដឹងជាអាទិ៍ថា ការរំលោភសិទ្ធិមនុស្សយ៉ាងកំរោល ឃោរឃៅ នៅតែត្រូវធ្វើទៅលើជនជាតិភាគតិច ហើយនិងការរើសអើងវប្បធម៌ សាសនា បន្តទៀត ។

ពួកជនរងគ្រោះទាំងនោះ ត្រូវគេសម្លុតគម្រាម មិនឲ្យនិយាយប្រាប់ពិភពខាងក្រៅពីភាពលំបាកលំបិន និងទុក្ខវេទនារបស់ពួកគេឡើយ ។ អំពើទាំងនេះមានភាពផ្ទុយគ្នាដូចមេឃនិងដី ទៅនឹងចម្លើយប្រទេសយៀកណាម ដែលផ្ដល់ឲ្យស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស កាលពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០២ ។

សេចក្ដីថ្លែងការណ៍ឲ្យដឹងទៀតថា ការរំលោភរបស់អាជ្ញាធរហាណូយទៅលើខ្មែរក្រោម មានរួមទាំងការសម្លាប់ ការលបចាប់ខ្លួនដោយស្ងាត់ ៗ លើក្រុមអ្នកដឹកនាំខ្មែរក្រោម ការវាយធ្វើបាប ឬ ប្រើជាតិគីមីធ្វើឲ្យខួរក្បាលអ្នកទោសខ្មែរក្រោមបាត់បង់សតិ បន្ទាប់ពីត្រូវដោះលែងចេញពីគុកវិញ...។ល។ និង។ល។

ចំណែកឯដីស្រែ ទីវត្តអារាមរបស់ខ្មែរក្រោមមួយចំនួនធំត្រូវបានបានអាជ្ញាធរក្រុងហាណូយ រឹបអូសធ្វើផ្លូវ ឬ ប្រព័ន្ធប្រឡាយទឹក ឬក៏ប្រគល់ទៅឲ្យជនជាតិយៀកណាម ដោយគ្មានការបង់ថ្លៃអ្វីបន្តិចបន្តួចទៅម្ចាស់ដើមដែលជាខ្មែរក្រោម ។ ហើយបើខ្មែរក្រោមចង់ប្រើប្រព័ន្ធសាងសង់ទាំងនោះ គេត្រូវតែចេញលុយទើបអាចប្រើបាន ។

ទាក់ទងលើការប្រតិបត្តិសាសនា សេចក្ដីថ្លែងការណ៍ឲ្យដឹងថា អាជ្ញាធរហាណូយបានចេញបញ្ជា កាលពីថ្ងៃ ១៨ មីនា ឆ្នាំ ២០០៤ ដោយបានរឹតបន្តឹងការគោរពពុទ្ធសាសនា ។ វត្តខ្លះត្រូវគេយកធ្វើជាគុក ។ កម្លាំងនគរបាលយៀកណាម បានត្រូវដាក់ពង្រាយតាមវត្តខ្មែរក្រោមនានា ដើម្បីតម្រូវឲ្យវត្តធ្វើតាមមាគ៌ាបក្សកុម្មុយនិស្ត ដែលដាក់ឲ្យអនុវត្ត ។

ក្នុងបញ្ហាសាសនាដដែលនេះ ក្រុងហាណូយបានបង្ខំឲ្យព្រះសង្ឃខ្មែរក្រោមចូលរួមក្នុងកងកម្លាំងយោធា និងហាមប្រាមមិនឲ្យគេនាំយកគម្ពីរព្រះត្រៃបិដក ចូលទៅតម្កល់ទុកក្នុងវត្តខ្មែរក្រោមជាដើម ៕

*អត្ថបទដកស្រង់ពីគេហទំព័រវិទ្យុអាស៊ីសេរី* www.rfa.org




**-វិទ្យុសំឡេងកម្ពុជាក្រោម** ជាសំឡេងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ផ្សាយចេញពីក្រុងវ៉ាស៊ីនតោន រដ្ឋធានីនៃសហរដ្ឋអាមេរិក សម្រាប់បម្រើដល់ប្រិយមិត្តអ្នកនិយមស្ដាប់ការផ្សាយរបស់វិទ្យុយើងខ្ញុំ ។

**-កម្មវិធីផ្សាយ** ៖ ផ្សាយក្នុងមួយសប្ដាហ៍ម្ដង រៀងរាល់ថ្ងៃអង្គារ ចាប់ពីម៉ោង ៩ ដល់ម៉ោង ១០ យប់ ម៉ោងនៅកម្ពុជាក្រោម តាមកម្ពស់រលកធាតុអាកាសខ្លី ១៥,៦៩០ គីឡូហ៊ើត ។

-ប្រិយមិត្ត ក៏អាចបើកស្ដាប់បានគ្រប់ពេល តាមរយៈគេហទំព័រ www.khmerkrom.org/radio ។

# ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
## ផ្ដោតការយកចិត្តទុកដាក់លើប៉ាពួខាងលិច

ក្រុមប្រឹក្សាសាសនាគ្រឹស្តពិភពលោក បានថ្លែងឲ្យដឹងពីចំណុចពាក់ព័ន្ធសំខាន់របស់ខ្លួន នៅក្នុងសម័យប្រជុំលើកទី ៦១ នៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលនិយាយទាក់ទងនឹងសិទ្ធិផ្នែកសេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ច នៃប្រជាជនប៉ាពួ នៅប្រទេសឥណ្ឌូនេស៊ី ។

ថ្មី ៗ នេះ ក្រុមប្រឹក្សាសាសនាគ្រឹស្តពិភពលោក បានបញ្ជូនអ្នកតំណាងសិទ្ធិមនុស្សរបស់ខ្លួនជាច្រើននាក់ ទៅចូលរួមក្នុងកិច្ចប្រជុំឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១២ មីនា ដល់ថ្ងៃទី ២២ មេសា ឆ្នាំ២០០៥ ។

ក្រុមប្រឹក្សាសាសនាគ្រឹស្តពិភពលោក នឹងស្នើដល់ឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ធ្វើការទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលនៃប្រទេសឥណ្ឌូនេស៊ី ដើម្បីពិភាក្សាអំពីសិទ្ធិរបស់ជនជាតិប៉ាពួ និងការទទួលនូវផលប្រយោជន៍ពីធនធានធម្មជាតិនានានៅតំបន់ប៉ាពួ ។

ការពិចារណាទៅលើសិទ្ធិផ្នែកសេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ចនៃប្រជាជនប៉ាពួ នឹងត្រូវបានដាក់ជូនឧត្តមស្នងការនៃអង្គការសហប្រជាជាតិ ពិនិត្យ និងយកទៅប្រកាសជាសាធារណៈនៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០០៥ ។ ការពិចារណានេះត្រូវបានផ្ដល់សិទ្ធិ ដោយព្រះវិហារគ្រឹស្តសាសនានៃប្រទេសអាឡឺម៉ង់ ដោយមានការជួយជ្រោមជ្រែងពីក្រុមប្រឹក្សាសាសនាគ្រឹស្តពិភពលោកផងដែរ ហើយត្រូវបានអនុវត្តដោយបណ្ឌិតសភា និងអ្នកការពារសិទ្ធិមនុស្សប៉ាពួ ។

នៅក្នុងអំឡុងកិច្ចប្រជុំ ឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ពីថ្ងៃទី ២-៤ ខែមេសា នេះ អ្នកតំណាងសាសនា ដែលបានចូលរួមក្នុងកិច្ចប្រជុំ នឹងធ្វើការទំនាក់ទំនង និងរិះរកយុទ្ធសាស្ត្រ ធ្វើយ៉ាងណាឲ្យស្ថានភាពសិទ្ធិមនុស្សនៅតំបន់ប៉ាពួមានលក្ខណៈល្អប្រសើរ ។

បន្ថែមពីលើនេះទៀត នៅថ្ងៃទី ៦ ខែមេសា ក្រុមប្រឹក្សាសាសនាគ្រឹស្តពិភពលោក នឹងប្រជុំដើម្បីពិភាក្សាគ្នាជាមួយគណៈថ្នាក់ដឹកនាំសាសនាគ្រឹស្តនានា ដើម្បីធ្វើកំណៃទម្រង់ជាមួយឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ៕

# សមាជិក សមាជិកា អង្គការយូអិនភីអូ មកប្រជុំនៅទីក្រុងហ្សឺណែវ

កាលថ្ងៃទី ១៤ មីនា ឆ្នាំ ២០០៥ សមាជិកសមាជិកាប្រតិភូសម្ព័ន្ធអន្តរជាតិសម្រាប់ការពារសិទ្ធិក្រុមជាតិពន្ធុ សាសនា ភាសា និងជនជាតិភាគតិច មកពីទូទាំងពិភពលោក បានមកចូលរួមក្នុងសម័យប្រជុំលើកទី ៦១ នៃឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ ។ កិច្ចប្រជុំនេះ ផ្ដោតការយកចិត្តទុកដាក់ជាសំខាន់ ទៅលើសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងនៃជនជាតិភាគតិច និងជនជាតិដើម ហើយនេះក៏ជាឱកាសដ៏មានសារៈសំខាន់ ចំពោះសមាជិកសមាជិកាទាំងឡាយដែលបានចូលរួមក្នុងវេទិកាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនេះ ។

ក្នុងកិច្ចប្រជុំមុន ៗ សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដែលទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសជាសមាជិកនៃអង្គការយូអិនភីអូ ត្រូវបានបណ្ដាអង្គការក្រៅរដ្ឋាភិបាល យកទៅដាក់ជូនឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សដើម្បីពិនិត្យ ។ របាយការណ៍ទាំងនេះ បានបញ្ជាក់អំពីការរំលោភសិទ្ធិមនុស្ស ដែលកំពុងតែកើតមានជារៀងរាល់ថ្ងៃនៅបណ្ដាប្រទេសពាសពេញពិភពលោក ។ នៅក្នុងកិច្ចប្រជុំនេះ សមាជិកសមាជិកាទាំងឡាយ នៃប្រតិភូសម្ព័ន្ធអន្តរជាតិសម្រាប់ការពារសិទ្ធិក្រុមជាតិពន្ធុ សាសនា ភាសា និង ជនជាតិភាគតិច នឹងមានឱកាសដើម្បីថ្លែង និងជូនឯកសារដោយផ្ទាល់ទៅកាន់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។

ថ្ងៃពុធ ទី ២៣ មីនា សមាជិកសមាជិកាទាំងអស់បានមកជួបជុំគ្នានៅសណ្ឋាគារ ផាឡែស៍ដឺណេសិន (Palais des Nations) ហើយបានធ្វើការឧទ្ទេសនាម បង្ហាញអំពីការអភិវឌ្ឍនៅក្នុងតំបន់របស់ពួកគេ និង បញ្ជាក់ពីគោលបំណងក្នុងការចូលរួមប្រជុំជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។ សមាសភាព នៅក្នុងកិច្ចប្រជុំនោះរួមមាន តំណាងមកពីប្រទេសអាវ៉ាស៍ Ahwaz, កាប៊ីនដា Cabinda, អ៊ីរ៉ាគី Iraqi, ទួកមិត Turk-met, កាមឺរូនខាងត្បូង Southern Cameroons ព្រមទាំងបណ្ដាសមាជិកនៃលេខាធិការដ្ឋានអង្គការយូអិនភីអូផងដែរ ។

ក្នុងរយៈពេលនៃកិច្ចប្រជុំនេះ សមាជិកទាំងឡាយបានផ្លាស់ប្ដូរគំនិតយោបល់ និងបទពិសោធន៍ទៅវិញទៅមក ហើយបានពិភាក្សាអំពីទុក្ខលំបាកវេទនា ដែលជាតិសាសន៍ខ្លួនកំពុងតែប្រឈមមុខ ។ សមាជិកដទៃទៀត ដែលនឹងត្រូវចូលរួមក្នុងកិច្ចប្រជុំឆ្នាំនេះ មានតំណាងនៃប្រជាជាតិ និងប្រជាជននៃទន្លេក្របី, ទួគីស្ថានខាងកើត, ខ្មែរកម្ពុជាក្រោម, អូហ្គូនី, អូរ៉ូម៉ូ និងហ្សាន ៕

*ប្រភពពីអង្គការ* UNPO

# រឿងកំពប់តែអុង

អត្ថបទកំណាព្យនេះ ត្រូវបានរក្សាទុកអក្ខរាវិរុទ្ធ
តាមច្បាប់ដើមទាំងស្រុង

## សាស្ត្រាវត្តក្រូច – រៀបរៀងដោយសាស្ត្រាចារ្យ ឃឹន សុខ

**(តពីលេខមុន)**

១៩៦-ទូនផ្កាចិន្តាស្រាលស្រាប់ ចូលចិត្តចងចាប់
សម្លាប់ដោយកាប់អាត្មា ។

១៩៧-ជ្រើសអស់ផ្កាជាសេណា ប្អូនៗក្លៀវក្លា
ក្រាបក្រាកាន់គ្រឿងគ្រប់ដៃ ។

១៩៨-គិតស្រេចរំពេចឆាប់រហ័ស ខ្លះទៅនៅនៃ
ផ្ទៃវាំងទាំងកាយា ។

១៩៩-ខ្លះទៅចាំនៅសាលា ប្រុងប្រៀបអាត្មា
ក្រឆាត់ក្រទូលមំម្លូន ។

២០០-ចក្រីក្រហោមធំធ្ងន ហេតុគ្រោះក្រខ្លួន
ជួបជួនជីវិតនិងក្ស័យ ។

២០១-ពំដឹងទោសទូទីទៃ តែងទៅសព្វថ្ងៃ
ប្រាស្រ័យគាល់មហាក្សត្រ ។

២០២-ប្អូនថ្ងៃនោះនៃក្រឡា ហោមទៅសាលា
ពិភក្សាក្តីអ្នកផង ។

២០៣-កូនក្មួយក្មេងៗទេសហោង ទើបទៅដល់ឆ្លង
ប៉ុនបងឡើងលើសាលា ។

២០៤-ដើងជាន់ជណ្តើរម្មិម្នា ទើបទៅទិមទ្វារ
ទូនផ្ការចាក់ធ្លាក់មកខ្មី ។

២០៥-សេណាចាមផ្កានៅដី ព្រួតវាយរឹងខ្មី
លុះបាត់ស្មារតីសូន្យសោះ ។

២០៦-ហើយទើបចាក់កកាលនោះ អូសទៅក្រៅស្មោះ
ចោលចោះបង្សៀតទៅខ្មី ។

២០៧-និយាយចែងចាយសេចក្តី ឯអង្គចក្រី
ប៉ែនបានឃ្មាតខ្មីលេលា ។

២០៨-ទៅដល់មណ្ឌលទីមទ្វារ ទើបពានសេណា
ចោមជុំអាត្មាច្រើនក្រៃ ។

២០៩-គេវាំងទ្វាររាំងនោះនៃ ប្រើងប្រែវិលវ័យ
ដៃដល់តប់ទាត់តតាំង ។



យួនយកក្បាលខ្មែរធ្វើជាម៉ុចង្ក្រានកល់ដាំតែអុង

២១០-ចក្រីបែនភិតភាំង លោលោតឡើងវាំង
រលះរលាំងលិកលាន ។

២១១-ខានតិចនិងលេចឡើងបាន ឯអស់ទាហាន
ព្រួតប្រាណប្រទប់ជុំវិញ ។

២១២-ឯអង្គចក្រីបែនមិញ និងលោលោតចេញ
ពុំរួចដូចចិន្តា ។

២១៣-ពលរេគេចោមជុំចាត ចាក់កាប់អាត្មា
គ្រាំគ្រាតំណំស្មើក្ស័យ ។

២១៤-សេណាគ្នាគេច្រើនក្រៃ ចក្រីបែនដៃ
ទទេតែទោះទាត់តប់ ។

២១៥-ទាត់ទៅត្រូវដួលសន្លប់ គ្នាគេច្រើនខ្ទប់
ប្រទប់ប្រទះរារាំង ។

២១៦-ចក្រីអន់អស់កំឡាំង និងប្រឹងប្រណាំង
តតាំងទុលទុពពុំបាន ។

២១៧-គេព្រួតវាយអន់អង្គប្រាណ ចោមចាប់ចងបាន
ដូចគំនិតគិតនោះ ។

២១៨-គេគិតកាប់ចាក់មិនចុះ មិនមុតមិនធ្លុះ

គេច្រានច្រមុជក្បិណក្បៀយ ។
២១៩-គេឲ្យអូសចោលក្នុងព្រៃ កូនក្មួយភិតភ័យ
រូតរត់ទីទៃគ្រប់គ្នា ។
២២០-ស្រេចហើយអស់អង្គសេណា នោះនាំគ្នីគ្នា
ទៅរើរិបទ្រព្យឥតសល់ ។
២២១-បញ្ជីត្រួតត្រាត្រិនពល នាំយកទៅដល់
ថ្វាយស្តេចដូចដោយចិន្តា ។
២២២-ទើបមានព្រះបន្ទូលថា ព្រះច័នទ្រាព្យា
ឲ្យអស់សេណានោះន័យ ។
២២៣-ស្រេចហើយព្រះបាទឧទៃយ តាំងទូនផនៃ
ឲ្យធ្វើយមរាជវិញស្នង ។
២២៤-ឯអង្គនាម៉ឺនដែលត្រង់ ងារថ្មីនោះហោង
ឥតហ្មងមន្ទិលទោសា ។
២២៥-សិងថ្កើងសើយយសស័ក្តា ដោយបុណ្យក្សត្រា
គុនគិតរាជការនិងនៅ ។
២២៦-លុះលង់ពីពង្សចោមចៅ    អង្គអាណុជនៅ
យូរទៅបន្តិចស្តេចបាន ។
២២៧-ជ្រួតជ្រាបសូភាពដើមដាន ជាព្រះរាមទាន
បន្ទូលទៅថ្កានយួនឱង ។
២២៨-តាគុនធំលុននៅក្នុង        ព្រៃនគរចង់
ឲ្យអង្គអាណុជស្តេចទៅ ។
២២៩-ឲ្យយួនយកអាណុជនៅ    ពីពង្សអង្គទៅ
ពុំចូលចិត្តនិងយួននោះ ។
២៣០-ស្តេចដិងដើមដល់ក្នុងពោះ រៀមពិតពុំស្មោះ
អង្គអាណុជនោះដឹងខ្លួន ។
២៣១-ស្តេចគិតគំនិតថៃថួន       រកពិរៀបខ្លួន
ទៅតាមអង្គស្ងួនរៀមរ៉ា ។
២៣២-ដល់ទៅចូលពឹងពាក់ ពុទ្ធិចៅជាតិជាក់
ជាខ្ញុំបង្កឹកកាយ ។
២៣៣-ពុទ្ធិចៅសួរទៅសព្វសាយ លួងពីពង្សកាយ
ក្រាបថ្វាយទូលសព្វសេចក្តី ។
២៣៤-អំពីក្រហោមចក្រី ដូចដើមសេចក្តី
ឥតបីឃ្លាងឃ្លាតអតីតា ។
២៣៥-កាលនោះព្រះចៅយុធ្យា ទ្រង់ព្រះចិន្តា
ថាឯអង្គច័នយល់ឆ្គង ។
២៣៦-ថាបើនាម៉ឺនមានហ្មង គិតក្បត់ម្តេចម្តង
ចងកាប់សម្លាប់បានហើយ ។
២៣៧-តួរខ្លួនចូលដល់ម្តេចឡើយ ស្បៀមស្ងាត់ព្រងើយ
កន្តើយពិតពុំនាំពា ។
២៣៨-កាលនោះព្រះចៅយុធ្យា ទ្រង់ព្រះចិន្តា
ថាបើដូច្នេះគួរអញ ។
២៣៩-ប្រើបញ្ញាយោមរាជចចេញ ទៅសាកសួរវិញ
ឲ្យដឹងដំណើរនោះកូវ ។
២៤០-គិតស្រេចស្តេចត្រាស់ឲ្យចៅ ពញ្ញាយោមរាជ
នៅថៃយណាម្ទុរុងមើងបីបាន ។
២៤១-មកដល់មណ្ឌលក្សត្រក្សាន ដល់ហើយស្តេចមាន
ព្រះរាជឱង្ការត្រាស់ថា ។
២៤២-ឲ្យនាំពលពាលយោធា មកសួររាជា
កក្រុងកម្ពុជាបូរី ។
២៤៣-រីឯអង្គពញ្ញាទាំងបី ឱនអង្គសិរសី
ស្តាប់ដឹងសេចក្តីសាស័ព្ទ ។
២៤៤-គ្រួចក្រាបស្រពាប់ឱនអ័ព្ទ ភិវាទគំរប់
ទទួលបន្ទូលឱង្ការ ។
២៤៥-ស្រាប់ស្រេចរំពេជលុតលា នាំពលយោធារ
យល់ជាមួយពាន់ប្លាយបាន ។
២៤៦-មកដល់មណ្ឌលទីស្ថាន ស្រុកន្ទាមាមាន
ហៅហិនអង្រៃនោះឯង ។
២៤៧-ទើបពញ្ញារុងមើងចាត់ចែង ជុំទប់អង្គឯង
ព្រះសរសម្តែងនាម្ទា ។
២៤៨-ឲ្យដើរបែកចេញពីគ្នា ពលពីរយហា
សិបសិងលេលាមកអាយ ។
២៤៩-ដើរផ្លូវត្រូវកំពង់ស្វាយ រាងរាបមកអាយ
ដល់ខែត្តបារាយឈប់នៅ ។
២៥០-សឹងគិតរាតត្បាតកំដៅ រាស្ត្រខ្មែរស្រុកក្រៅ
ក្នុងខែត្តទាបនឹងភូមិធំ ។
២៥១-ឲ្យរើសយកកូនក្រមុំ រាស្ត្រខ្មែរទៅជុំ
ទៅភូមិបារាយណ៍បាណ៌ក ។
២៥២-មកភូមិទ្រាលប្រិចរើសយក បាននាំចូលមក
ជួបជុំនៅភូមិបារាយណ៍ ។
២៥៣-ឯអស់អង្គអាពុកម្តាយ សឹងសោកសឹងស្តាយ

អាណិតដ្បិតបុត្តសង្សា ។
២៥៤-យកដៃដាល់តប់ឱរា ក្ដួលក្ដៅខ្លោចផ្សា
ស្ទើរនិងមរណាអស់ប្រាណ ។
២៥៥-តំណើរនោះស្លេះឈប់ខាន ទើបទៅនិទាន
ឯពញាយោមរាជនោះវិញ ។
២៥៦-ក្រោយចាត់សរសម្ដែងចេញ យមរាជឯងមិញ
ថៃយណាមនៅរុងមឿងមក ។
២៥៧-បានដល់មណ្ឌលវាំងរក ស្ដេចពុំឃើញបក
សំបុត្រច្បាប់មួយទូលទៅ ។
២៥៨-ឲ្យអស់អាមាត្រក្នុងក្រៅ ក្រាបទូលព្រះចៅ
ដោយនូវដំណើរអក្ខរា ។
២៥៩-ស្ដេចបានដឹងតាមអតិតា អង្គច័ន្ទក្សត្រា
ត្រៃចត្រូវទៅយួនស្មោះស្ម័គ្រ ។
២៦០-ស្រេចស្ដេចប្រើទៅស្មៀនស្មេរម្នាក់ ធ្វើបន្ទូលតាក់
ប្រើតំណើរព្រះអាមាត្រ ។
២៦១-អញ្ជើញព្រះបន្ទូលសីហនាដ្ឋ ដល់ហើយឱនអង្គ
ក្រួចក្រាបទូលថ្វាយរាជសារ ។
២៦២-ទៅស្ដេចទេព្ដាពុំលង់ ដល់ហើយឱនអង្គ
ក្រួចក្រាបទូលថ្វាយរាជសារ ។
២៦៣-រីឯអង្គស្ដេចទេព្ដា ឲ្យស្មៀនសូតសារ
អស់អាតំណើរសេចក្ដី ។
២៦៤-ស្រាប់ស្រេចស្ដេចបន្ទូលខ្ទី ដោយដើមសេចក្ដី
ពីបូរីបូរាណរាជា ។
២៦៥-ថាឯស្ដេចខ្មែរនោះណា នគរតូចជា
ឲ្យទុកជាកូនពុំងា ។
២៦៦-នគយួនយើងនៅអាយ លោកទុកជាម្ដាយ
បង្កើតពិតពុំដទៃ ។
២៦៧-នគរពុទ្ធិចៅនោះន័យ ពិតពុំដទៃ
ទុកលោកស្មោះស្មើរអាពុក ។
២៦៨-បើកូនមាននោកនុក ខុសនិងអាពុក
ទោស្សទុកទៅឱបជើងម្ដាយ ។
២៦៩-ឲ្យអង្គអាពុកនៅអាយ គុណាគិតវេងឆ្ងាយ
រំសាយលេងទោសទាន់ទុក ។
២៧០-បើខុសនិងម្ដាយមិនសុខ រតរកអាពុក
ទោសទុក្ខឲ្យម្ដាយលេងចេញ ។

២៧១-ស្ដេចបន្ទូលថានោះមិញ ធ្វើបន្ទូលវិញ
ឲ្យអាមាត្រនាំទៅ ។
២៧២-ទូលទាល់សម្ដេចពុទ្ធិចៅ ស្ដេចជ្រាបដោយនូវ
តម្ងៃដើមដានអក្ខរា ។
២៧៣-ស្ដេចប្រើបំរើម្ទីម្នា បនថយអស់ពញា
យោមរាជរុងមឿងថៃយណាម ។
២៧៤-យោមរាជរុងមឿងសឹងតាម ទាំងពញាថៃយណាម
សឹងតាមបំរើពុទ្ធិចៅ ។
២៧៥-លេលាយាត្រាវិលទៅ ទីស្ថានលំនៅ
បង្គំពុទ្ធិចៅឥតហ្មង ។
២៧៦-រីឯដំណើរទំនង រាជសារនោះហោង
ជាសុខសួស្ដីខ្មែរមមក្សាន្ត ។
២៧៧-ទុកស្លេះនៅនោះនិទាន ទៅឯក្សត្រក្សាន្ត
ព្រះបាទឧទៃរាជា ។
២៧៨-ក្រោយសាព្រះអាមាត្រលា នោះស្ដេចទេព្ដា
ចាត់ប្រើឲ្យអុងតាគុន ។
២៧៩-នាំស្ដេចមកទីតម្បន់ ឯអុងតាគុន
ក្រាបងើបលុតលាចរចេញ ។
២៨០-មកដល់មណ្ឌលស្ដេចវិញ វាំងចាស់នោះមិញ
ឯអុងតាគុនគិតថា ។
២៨១-និងស្ដេចឲ្យប្រើសេណា មន្ត្រីយោធារ
ធ្វើវាំងនៅនាភ្នំពេញ ។
២៨២-ឲ្យរើធ្វើជាថ្មីវិញ អុងតាគុងមិញ
ក៏ទុកអុងឲ្យមួយឈ្មោះ ។
២៨៣-បាហោនៅឈរចំពោះ រក្សាស្ដេចនោះ
នៅជាឯជើងវាំងវិញ ។
២៨៤-ឯវាំងមហាក្សត្រនោះមិញ អគ្នេយភ្នំពេញ
ជិតមាតទន្លេ៤មុខ ។
២៨៥-គិតស្រេចអុងតាគុងទុក រាជ្កាគ្រប់មុខ
ទុកលើល្បួងនិងអុងស្មោះ ។
២៨៦-រីឯអុងតាគុងនោះ លាល្បួងបរបោះ
ចេញទៅនៅព្រៃគរ ។
២៨៧-ឯល្បួងនៅអុងបាហោ តែងប្រើទៅមក
ផ្កាញ់ព្រៃនគរពុំតេច ។

**(នៅមានត)**

កំណាព្យ

# បងខុសហើយអូន !

*រាត្រីភ្នំពេញ ទី ១១ មីនា ២០០៥*

-នៅលើវេហាស៍នាលំហ ព្រះនិសាករចរគ្រឿនៗ
ពពករសាត់ផាយផាត់លឿន តាមល្បឿនព្រះពាយពេលរាត្រី។

-ក្រឡេកឯនាយឃើញខ្ទមស្លឹក សសរកូនផ្ទឹកខ្ពស់ពីដី
លើទួលជាយដែនដើមបុរី ខណ្ឌក្រិចំណាំព្រៃខ្មែរយួន ។

-ដំបូលស្លឹកត្នោតទើបប្រក់ថ្មី តែចេះស្រដីទាស់ផ្ទួនៗ
រិះគន់ជញ្ជាំងនៅក្រោមខ្លួន យីស ! អាមកពួននាំអញក្ដៅ ។

-អញលបគយគន់កើតសង្ស័យ ច្រើនយប់ច្រើនថ្ងៃក្រៃម្ទូម៉ៅ
ឯងកុំបន្លំ ស ជា ខ្មៅ ច្បាស់ផៅក្រៅស្រុកមុខក្រៅសាសន៍ ។

-ខុសទាំងរូបរាងទាំងសម្បុរ ច្បាស់ជាមានកលកិច្ចបោកប្រាស
ឯងមកពីណាកុំថាផ្កាស ពូជពង្សក្រៅសាសន៍ ឬយ៉ាងណា ។

-ជញ្ជាំងព្រហើយកើតសង្វេគ បង្ហូរទឹកភ្នែកណែនឱរា
តើខ្ញុំខុសអ្វី ? ខុសត្រង់ណា ? ឬក៏ដូនតាគិតការខុស ។

-ថ្លែងប្រាប់ស្លឹកត្នោតជាដំបូល សូមបងកុំពោលពាក្យនាំទុស្ត
យើងផ្ដល់ផលច្រើនជូនដល់មនុស្ស លង់លុះមរណាមកពង្រាត់ ។

-ខ្ញុំរស់ឯដែនសណ្ដក្រោម ឈើព្រៃព្រួតចោមជុំរុំព័ទ្ធ
ដោយសារពូជពង្សខ្ញុំប្រឹងវត្ត ស៊ូទ្រាំខាំមាត់មិនវាចា ។

-ទោះមនុស្សកាប់ស្លឹកច្រៀកឆាងចង ទោះក្មេងជាន់ឆ្លងក៏មិនថា
នាពេលទឹកធំខែវស្សា ក្មេងទៅសាលាខ្ជិលលុយទឹក ។

-ខ្ញុំរស់លើដីកេរមនោរម្យ តែបែរទុក្ខទំទាំងល្ងាចព្រឹក
រស់រងកម្មពៀរជាពន្លឹក គួរនឹកស្រណោះដល់ញាតិផៅ ។

-បងត្នោតយល់ហើយកុំគ្នាន់គ្នេរ យើងដូចគ្នាទេទាំងកូនចៅ
ត្រូវមនុស្សដេរដោតដើមដំបៅ ស្លឹកស្ងៅលូតលាស់មនុស្សកាប់ប្រើ ។

-ត្នោតសោតព្រសព្វសព្ទសែនខ្វល់ រកកលអ្នូលអាក់ពុំគួរបើ
ដៀលតិះពូជពង្សពុំប្រសើរ នេះតើហេតុខ្លៅបង់ផៅផង ។

-ត្នោតស្លឹកនឹកភ្នកសួររកឈ្មោះ ប្អូនអើយកុំមោះខឹងនឹងបង
តើប្អូនឈ្មោះអ្វីទៅន្ទួនល្អូង ប្រាប់បងកុំលាក់ណាប្អូនណា ។

-ខ្ញុំនេះឈ្មោះចាកណាបងត្នោត យើងគួរឈប់ឆោតខំរក្សា
ចំណាងសាមគ្គាស្នងដូនតា កៀកស្មាស្លាប់រស់ព្រោះរឿងពូជ ៕

## វេទិកា គំនិតជាតិ

# ខ្មែរកម្ពុជាក្រោមមិនត្រូវការរស់ក្រោមរបបអាណានិគម

ការងើបឡើងដើម្បីទាមទារឯករាជ្យ នៃប្រជាជាតិបិតនៅក្រោមរបបអាណានិគម បានបង្កជាចលនាទប់មិនឈ្នះ ដែលជាផលវិវត្តន៍នៃប្រវត្តិសាស្ត្រ ។

សង្គ្រាមនៅឥណ្ឌូចិន ដែលបានផ្ទុះឡើងចាប់តាំងពីឆ្នាំ ១៩៤៥ មកនោះ បានអូសបន្លាយហូតមកដល់ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៥៤ ទើបសន្និសីទមួយត្រូវបានបង្កើតឡើង ដើម្បីពិភាក្សាអំពីបញ្ហាសន្តិភាពនៅឥណ្ឌូចិន នាទីក្រុងហ្សឺណែវ ប្រទេសស្វីស ។

ស្របពេលជាមួយគ្នានេះ សហព័ន្ធឥណ្ឌូចិនមួយ ដែលស្ថិតនៅក្រោមអំណាចអគ្គទេសាភិបាល (Gouverneur General) និងអំណាចអាណានិគមបារាំងក៏បានផុតរលត់ទៅដែរ ។ ដែនដីទាំង ៥ នៅក្នុងសហព័ន្ធឥណ្ឌូចិន គឺ កូសាំងស៊ីន ប្រទេសអណ្ណាម ប្រទេសតុងកឹង ប្រទេសលាវ និងប្រទេសកម្ពុជា ដែលសុទ្ធតែមានលក្ខន្តិកៈនយោបាយផ្សេង ៗ គ្នា បានរួចផុតពីអំណាចអាណានិគមបារាំងរៀង ៗ ខ្លួនដែរ ។

បណ្ដាប្រទេសនៅក្នុងសហព័ន្ធឥណ្ឌូចិន ដែលបារាំងដាក់អាណានិគមនោះ បារាំងខ្លួនឯងដឹងច្បាស់ណាស់ថា ដែនដីនិមួយ ៗ ជារបស់ប្រទេសណា ជាតិសាសន៍ណាពិតប្រាកដ និងអនុវត្តលក្ខន្តិកៈនយោបាយបែបណាសម្រាប់មនុស្សក្នុងដែនដីទាំងនោះ ហើយនៅពេលដែលបារាំងបញ្ចប់អាណានិគមរបស់ខ្លួនហើយនោះ គួរណាស់តែបារាំងប្រគល់ទៅឲ្យម្ចាស់ដើមគេវិញ «ដូចជាដីខ្មែរកម្ពុជាក្រោមដែលបារាំងហៅថា កូសាំងស៊ីន ជាដីរបស់ប្រទេសកម្ពុជា ឬ ខ្មែរ–កម្ពុជាក្រោម» បើបារាំងគ្មានលទ្ធភាពធ្វើអាណានិគមបន្តទៅទៀតបានទេនោះ គួរតែប្រគល់ទឹកដីនេះទៅឲ្យប្រទេសកម្ពុជា ឬ ខ្មែរកម្ពុជាក្រោមដែលជាម្ចាស់ដើមពិតប្រាកដវិញ មិនគួរណាបារាំងប្រគល់ទឹកដីនេះទៅឲ្យស្ដេចយួន បាវ ដាយ តាមសន្ធិសញ្ញាចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ១៩៤៩ សោះឡើយ ។

ករណីដែនដីកម្ពុជាក្រោមនេះ បើជាទឹកដីរបស់ប្រទេសបារាំងវិញ ហើយឧបមាថា ប្រទេសអាល្លឺម៉ង់ចូលឈ្លានពាន ត្រួតត្រាធ្វើអាណានិគម លុះពេលអាល្លឺម៉ង់ដកអាណានិគមចេញ អាល្លឺម៉ង់ចុះសន្ធិសញ្ញាប្រគល់ទឹកដីប្រទេសបារាំង ទៅឲ្យប្រទេសស្វីសវិញនោះ សួរថា តើប្រជាជនបារាំងពេញចិត្តដែរឬទេ ? សុខចិត្តដែរឬទេ ?

ប្រទេសកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ អតីតព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គធ្វើយុទ្ធ–នាការទាមទារឯករាជ្យបានពេញបរិបូរណ៍ នៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ មុនសន្និសីទក្រុងហ្សឺណែវមួយឆ្នាំ បើមិនដូច្នេះទេ ប្រហែលជានៅក្នុងសន្និសិទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ នោះ បារាំងយកទឹកដីកម្ពុជាទាំងអស់ប្រគល់ទៅឲ្យវៀតណាមផងក៏មិនដឹង ។

បញ្ហាដីខ្មែរក្រោមនេះ បានជាបទពិសោធន៍មួយសម្រាប់បណ្ដាប្រទេសនៅលើសកលលោក ហើយបណ្ដាប្រទេសដែលស្នេហាសន្តិភាព និងយុត្តិធម៌ ជាពិសេសអង្គការសហប្រជាជាតិ គួរតែចាត់វិធានការណ៍យ៉ាងណាឲ្យមានប្រសិទ្ធភាព ដើម្បីរំដោះបងប្អូនប្រជា–ពលរដ្ឋខ្មែរក្រោមជាម្ចាស់មាតុភូមិ ឲ្យរួចផុតពីក្រញាំបិសាចអាណា–និគមបរទេស និងដើម្បីបើកឱកាសឲ្យប្រជាជាតិខ្មែរក្រោមបានស្គាល់នូវពន្លឺសេរីភាព រស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរ មានសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយដោយសារស្នាដៃយួន ប្រជាជាតិខ្មែរក្រោមត្រូវរស់នៅក្រោមស្បែអន្ធការ រងទុក្ខវេទនាគ្រប់បែបយ៉ាង មិនដែលស្គាល់ឡើយ នូវអ្វីដែលគេហៅថាសិទ្ធិសេរីភាពនោះ ។ ពេលនេះព្រះអាទិត្យរះហើយ ស្បែអន្ធការត្រូវកំចាត់បង់សូន្យ ខ្មែរកម្ពុជាក្រោមក៏មិនត្រូវរស់នៅក្រោមនឹមដែកអាណានិគមយួនទៀតដែរ ខ្មែរក្រោមត្រូវមានសិទ្ធិក្នុងការសម្រេចវាសនាខ្លួនដោយខ្លួនឯងជាដាច់ខាត ។ បើមិនដូច្នោះទេ ប្រជាជាតិខ្មែរក្រោមនឹងជួបប្រទះនូវមហន្តរាយយ៉ាងធ្ងន់ធ្ងរឲ្យរង្គោះរង្គើដល់ស្ថិរភាពជាតិសាសន៍ខ្មែរជាក់ជាមិនខាន ។

ក្នុងនាមខ្មែរក្រោមម្នាក់ ខ្ញុំសូមសម្ដែងការគាំទ្រលោកម៉ារីណូ ប៊ូស្គាគិន ប្រធានអង្គការ UNPO ដែលបានធ្វើលិខិតឆ្ពោះតម្រង់ទៅក្រុងហាណូយ កាលពីខែកញ្ញា ឆ្នាំ ២០០៣ លើកឡើងនូវសោកនាដកម្មធំទាំង ៦ ដែលខ្មែរក្រោមយើងជួបប្រទះរៀងរាល់ថ្ងៃ ហើយលោកបានស្នើឲ្យ ៖

១–លុបបំបាត់របបអាណានិគម នៅលើទឹកដីកម្ពុជាក្រោម ដែលមានទំហំ ៦៨,៦០០ គីឡូម៉ែត្រក្រឡា គឺទូទាំងភូមិភាគខាងត្បូងវៀតណាមបច្ចុប្បន្ន ។

២–ដាក់ទឹកដីកម្ពុជាក្រោម នៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ តាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ជំពូកទី ១១,១២ និង ១៣ ដើម្បីបង្កើតឲ្យមានបរិយាកាសនយោបាយសេរី និងតម្លាភាព ដែលអនុញ្ញាតិឲ្យខ្មែរកម្ពុជាក្រោមអនុវត្តនូវសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ៕

*ធ្វើនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០០៥*

***ថាច់ សុរិយា***




**បញ្ញាសជាតក**
**រឿងទី ១៥**

ជាស្នាដៃនិពន្ធរបស់លោក **ញ៉ុក ថែម**
បោះពុម្ពលើកទី ១ នៅភ្នំពេញ ឆ្នាំ ១៩៥៩

# រឿងសុវណ្ណកុមារ

អតីតេ ក្នុងកាលកំបាំងបាត់ស្ងាត់យូរអង្វែងមកហើយនោះ មានព្រះមហាក្សត្រមួយអង្គ ព្រះនាមមហាភត្ត គ្រងរាជ-សម្បត្តិក្នុងនគរពារាណសី មានព្រះអគ្គមហេសីព្រះនាមចន្ទាទេវី ជាស្ត្រីប្រកបដោយកល្យាណធម៌ប្រពៃថ្លៃថ្នូរ ជាទីសព្វព្រះទ័យនៃព្រះរាជស្វាមីក្រៃលែង ។ ទ្រង់មានព្រះរាជបុត្រមួយអង្គព្រះនាមសុវណ្ណកុមារ ៗ មានវ័យចំរើនឡើង បានសិក្សាសិល្បសាស្ត្រផ្សេង ៗ សព្វគ្រប់ ជាពិសេស ទ្រង់ចេះស្ទាត់ជំនាញខាងសិល្បធ្នូ ក្នុងគំរប់ព្រះជន្ម ១៦ វស្សា ។

សម័យថ្ងៃមួយ ព្រះបាទមហាភត្តស្ដេចលើកចតុរង្គ-សេនា ព្រមទាំងភ្លេងតូរ្យតន្ត្រីគ្រប់ប្រភេទ ទៅប្រពាតកំសាន្តឆ្នេរមហាសមុទ្រ ។ ព្រះសុវណ្ណកុមារ ក៏ស្ដេចយាងទៅជាមួយនឹងព្រះវររាជមាតា-បិតាដែរ ហើយទ្រង់មានបំណងចង់ស្ដេចយាងទៅប្រពាតនៅកណ្ដាលមហាសមុទ្រ ។ ដោយតេជៈបារមីនៃព្រះរាជកុមារ ពួកទេពតារក្សាសមុទ្របាននាំដំរីសសុទ្ធមួយមកថ្វាយទ្រង់ ៗ ព្រមដោយសេនាយោធា ស្ដេចឡើងគង់លើព្រះទីនាំងគជេន្ទ្រយាងចុះទៅក្នុងសមុទ្រ ។ ឯគជសារមានមុខឆ្ពោះទៅត្រង់កន្លែងណា ទឹកសមុទ្រក៏បែកខ្វែកជាពីចំណែកដូចជាជញ្ជាំងផ្ទះ ។ ឯនាងសមុទ្ទកញ្ញាទាំងឡាយ ក៏រោយរាយលំអិតគន្ធ-ពិដោរ យកកម្រងផ្កាមាសបញ្ចពណ៌ ព្យួរនៅសងខាងនៃជញ្ជាំងទឹកសមុទ្រ ។ ឯស្ដេចនាគនាំនាគីបរិវារមកហែហមអង្គព្រះរាជកុមារ ។ ពេលសោយទ្រង់សោយតែភោជនាហារ ដែលពួកនាងសមុទ្ទកញ្ញា នឹងកញ្ញានាគីរៀបចំថ្វាយ ទ្រង់បានក្រសាលសប្បាយក្បេមក្សាន្តក្នុងមហាសមុទ្រអស់កំណត់ ៣ ថ្ងៃ ។

ព្រះបាទមហាភត្តនឹងព្រះនាងទេវី លុះព្រះរាជបុត្របាត់យូរថ្ងៃពេក ទើបទ្រង់ចាត់បម្រើឲ្យតាមព្រះរាជបុត្រ ៗ ទ្រង់មានបន្ទូលលាពួកសមុទ្ទទេវតានិងនាគរាជ ហើយស្ដេចព្រមដោយរាជបរិវារត្រឡប់មកថ្វាយបង្គំព្រះវររាជមាតា-បិតាឯឆ្នេរសមុទ្រ ហើយថ្វាយពេជ្រនិលចិន្ដាសព្វពិធរ័ត្នផង ដែលសមុទ្ទទេវតានិងនាគរាជបានថ្វាយទាំងប៉ុន្មាន ដល់ព្រះជនក-ជននីរបស់ទ្រង់ រួចស្ដេចលើករ័ពត្រឡប់មកព្រះរាជធានីវិញ ដោយសិរីសួស្ដី ។

ចំណេរកាលតមក មានឈ្មួញសំពៅ ៥០០ បើកក្ដោងចេញទៅសីហឡទ្វីប ដើម្បីធ្វើជំនួញ ហើយនិយាយសរសើរគជសារសសុទ្ធរបស់ព្រះសុវណ្ណកុមារនៃក្រុងពារាណសី ។ ដំណឹងនេះបានជ្រួតជ្រាបដល់ព្រះបាតភជេសុរាជនៃសីហឡទ្វីប ហើយត្រាស់ហៅយោធាទាំង ៤ នាក់ ដែលភ្លៀវក្លាអាចសម្រេចកិច្ចសព្វគ្រប់ប្រការមកបង្គាប់ថា “ចូរអ្នកទាំងឡាយចេញទៅនគរពារាណសីជាមួយនឹងពួកឈ្មួញសំពៅ ហើយក្រាបទូលស្ដេចមហាភត្តរាជថា ៖ ព្រះបាទភជេសុរាជ នៅសីហឡទ្វីប មានអានុភាពច្រើន មានតេជៈច្រើន មានពលច្រើនឥតមានស្ដេចណាប្រៀបផ្ទឹមស្មើឡើយ ឥឡូវនេះទ្រង់មានបញ្ជាថា សូមឲ្យព្រះអង្គនាំដំរីសសុទ្ធ ប្រកបដោយលក្ខណៈគ្រប់ប្រការទៅថ្វាយព្រះរាជាជាម្ចាស់នៃយើង បើមិនដូច្នោះទេ ទ្រង់នឹងធ្វើឲ្យនគរពារាណសីនេះវិនាសខ្ទេចខ្ទីពុំខាន” ។ យោធាទាំងបួនក៏ចេញទៅនគរពារាណសី ឡើងគាល់ព្រះបាទមហាភត្តរាជ ហើយក្រាបទូលថ្លែងព្រះឱង្ការសព្វសេចក្ដី ។ ព្រះចៅក្រុងពារា-ណសី ទ្រង់មានសេចក្ដីព្រួយបារម្ភក្រៃលែង ទើបត្រាស់ហៅប្រជុំសេនាបតី ឧបរាជ បុរោហិត នឹងព្រះរាជបុត្រ ទ្រង់បានថ្លែងប្រាប់ពីព្រះឱង្ការនៃព្រះបាទសីហឡទ្វីបសព្វគ្រប់ ។ ពួកសេវកាមាត្យទាំងនោះ បានឮដូច្នេះ ក៏គិតភ័យភាំងស្មារតីនៅតែស្ងៀមរៀងខ្លួន ។

គ្រានោះ ព្រះសុវណ្ណកុមារ បានទ្រង់ជ្រាបហេតុភេទដូច្នេះហើយ ក៏ក្រាបបង្គំទូលព្រះវររាជបិតាថា “សូមទ្រង់មេត្តា

ប្រោស សូមព្រះវរបិតាកុំព្រួយបារម្ភឡើយ សូមទ្រង់គង់ជាសុខសប្បាយចុះ ទូលព្រះបង្គំសូមទទួលធានានឹងទៅនាំយកស្ដេចភជេសុរាជ ព្រមទាំងពួកពលយោធាមកក្រាបថ្វាយបង្គំព្រះបាទា ព្រះអង្គឲ្យទាល់តែបាន” ។ ឯពួកអាមាត្យមុខមន្ត្រី បានស្ដាប់ព្រះបន្ទូលនេះហើយ ក៏មានសេចក្ដីត្រេកអរសោមនស្សទាំងអស់គ្នា នាំគ្នាថ្វាយសព្ទសាធុការពរដល់ព្រះរាជកុមារ ។ ព្រះវររាជបិតាមានព្រះហឫទ័យត្រេកអរណាស់ ទ្រង់ឲ្យចាត់ចែងធ្វើពិធីរាជាភិសេកព្រះសុវណ្ណកុមារឲ្យឡើងគ្រងរាជសម្បត្តិ ជាតំណាងព្រះអង្គតទៅ ។ ព្រះសុវណ្ណកុមារ លុះបានរាជាភិសេកហើយ មានចតុរង្គសេនាចោមរោមដង្ហែព្រះអង្គចេញទៅ នៅពេលប្រកបដោយជោគជ័យល្អ ក្បួនទ័ពព្រះរាជាព្រមដោយស្វេច្ឆ័ត្រក្លស់ក្លំអភិរម្យ ទង់ជ័យព្រមទាំងអាវុធយុទ្ធភ័ណ្ឌភ្លឺផ្លេកព្រោងព្រាត ហាក់ដូចពពួកផ្កាយលើផ្ទៃវេហាស៍ ។

ព្រះបាទសុវណ្ណកុមារ មុនទ្រង់លើកទ័ពចេញទៅ ទ្រង់បានត្រិះរិះថា “សម្បត្តិ សុខ សុភមង្គលនឹងឫទ្ធិតេជៈទាំងឡាយកើតឡើងដោយអនុភាពនៃបុណ្យ ដូច្នេះគួឲ្យពួកពលសេនាធ្វើបុណ្យសិន ព្រោះបុណ្យតែងរក្សាការពារអ្នកធ្វើបុណ្យឲ្យផុតពីក្ដីអន្តរាយ” ហើយទ្រង់បានចាត់ចែងធ្វើបង្ហាន់បិណ្ឌបាត្រប្រគេនដល់ព្រះសង្ឃ ប្រគេនទេយ្យទានផ្សេង ៗ ដល់ព្រះសង្ឃឲ្យសាងវិលុកចេតិយ ហើយទ្រង់រៀបគ្រឿងភ្ញីផ្កាបូជាទ្រង់បានសមាទានសីល ស្ដាប់ធម៌ទេសនា ទ្រង់បានព្រះរាជ-ទានអាហារ បំណីសំពត់អាវសារស្បៃជាដើម ដល់ស្មូមយាចកទាំងឡាយ ហើយទ្រង់បានជ្រួចទឹកឧទ្ទិសផលដល់សត្វលោកទូទៅ ។

ព្រះបាទសុវណ្ណកុមារទ្រង់បានលើកទ័ពចេញទៅ ដរាបដល់ត្រើយសមុទ្រ នៅពេលអធ្រាត្ររាត្រី ទើបព្រះនរបតីទ្រង់ព្រះបិន្ដាថា “ស្ដេចភជេសុរាជ មានឫទ្ធីអានុភាពដូចម្ដេចអេះ ?” ។ កំពុងទ្រង់ព្រះបិន្ដាដូច្នេះ ស្រាប់តែព្រះឥន្ទ្រាធិរាជទ្រង់នាំមកនូវធ្នូ ១ មានសរ ៥ មកថ្វាយទ្រង់ ដែលជាអាវុធទិព្វវិសេសក្រៃលែង ។ សរមួយនោះបាញ់ទៅបានចម្ងាយមួយយោជន៍ មានឫទ្ធិអាចកាត់ក្បាលមនុស្សនឹងទេពតាបានដូចបំណង ។ សរមួយទៀត បាញ់ចេញទៅកើតជាយានជំនិះ ។ សរមួយទៀតបាញ់ចេញទៅកើតជាវិមានអណ្ដែតលើអាកាស ។ សរមួយទៀតបាញ់ទៅកើតជាភ្នក់ភ្លើងយ៉ាងសាហាវ ។ សរមួយទៀត បាញ់ត្រូវមុតសាច់ហាមហើម លុះដល់កំណត់ប្រាំពីរថ្ងៃទើបស្លាប់ ។ ព្រះឥន្ទ្រាធិរាជទ្រង់បានប្រទានធ្នូសរទិព្វនោះហើយទើបទ្រង់ថ្វាយសព្ទសាធុការពរ ទ្រង់បានប្រសិទ្ធិជោគជ័យថ្វាយហើយស្ដេចលាត្រឡប់ទៅឋានវិមានរបស់ព្រះអង្គវិញ ។

គ្រានោះ ព្រះមហាក្សត្រទ្រង់ត្រួតត្រាពួកពលទាំងឡាយ ទ្រង់ទតឃើញមានរបៀបរៀបរយល្អហើយ ទើបទ្រង់នាំទ័ពចុះសំពៅនៅពេលមាននក្ខត្តឫក្សល្អ បើកក្ដោងលឿនស្លៅសំដៅកោះសីហឡទ្វីប ដល់ហើយទ្រង់បានបញ្ជូនរាជទូតឲ្យទៅទូលព្រះបាទភជេសុរាជថា “ព្រះបាទសុវណ្ណកុមារជាម្ចាស់យើងទ្រង់មានឫទ្ធិអំណាចអាចញាំញី ពួកសត្រូវគ្រប់ទិសត្រឹមត្រូវដោយកូនសរមួយរបស់ព្រះអង្គ ឥឡូវស្ដេចមកដល់ហើយ សូមព្រះអង្គម៉ឺម្នាចេញទៅថ្វាយបង្គំសូមអាយុជីវិត ឬមួយបើព្រះអង្គអាងមហិទ្ធិឫទ្ធិ ក៏សូមព្រះអង្គទ្រង់គិតរៀបចំគ្រឿងយុទ្ធ ចេញតតាំងច្បាំងចុះ” ។ ក្នុងខណៈនោះ ព្រះបាទសុវណ្ណកុមារ ទ្រង់បានថ្លែងសរជាអាវុធទូតមួយទៀត ទ្រង់បានផ្ដាំសរថា “នែសរដ៏ចម្រើន ចូរឯងទៅឋិតជិតគុម្ពត្រចៀកស្ដេចភជេសុរាជ ហើយគម្រាមថា នែស្ដេចកំណាច បើប្រស្ទែងមិនរៀសរៃទៅថ្វាយបង្គំព្រះបាទាព្រះរាជាជាម្ចាស់យើងទេ យើងនឹងកាត់ក្បាលទៅថ្វាយទ្រង់ឥឡូវនេះឯង” ។ សរនោះ ក៏ធ្វើតាមព្រះរាជបញ្ជា ព្រះមហាក្សត្រ ។ ព្រះបាទភជេសុរាជ ទ្រង់មានសេចក្ដីភិតភ័យក្រៃពេក ប៉ុន្តែទ្រង់ខំធ្វើកិរិយាកំឡាខាងក្រៅឲ្យមើលឃើញថា ទ្រង់មិនខ្លាចមិនតក់ស្លុត ហើយទ្រង់ហៅប្រជុំសេនាយោធា ដែលក្លា-ហានទាំងប៉ុន្មាន ដើម្បីទប់ទល់ ។ ព្រះបាទសុវណ្ណកុមារ ក៏បានថ្លែងសរមួយទៀតទៅកាត់សក់មនុស្សទាំងអស់ក្នុងព្រះនគរ ធ្វើឲ្យត្រងោលត្រងិលទាំងអស់គ្នា ហើយត្រឡប់មកចូលបំពង់វិញ ។ មហាជនផង ក៏ភិតភ័យតក្កមារាល់គ្នា ។ ព្រះមហាក្សត្រទ្រង់បានថ្លែងសរមួយទៀត កើតជាយានមានរាជរថទឹមសេះសឹងសសុទ្ធឬ ៗ មានភ្លេងរបាំតូរ្យតន្ត្រី មានស្រីអប្សររាំច្រៀងក្នុងរាជរថហោះប្រទក្សិណខាងក្រៅនគរ ៣ ជុំ ។ ទ្រង់បានថ្លែងសរមួយទៀតបង្កើតជាអណ្ដាតភ្លើងឆេះឡើងសន្ធោសន្ធៅ ក្រឡឹង

ខាងក្រៅនគរ ៣ ជុំហើយត្រឡប់ចូលបំពង់វិញ ។ អាណាប្រជានុរាស្ត្រ ក៏ភ្ញាក់ផ្អើលច្រួលច្របល់ពកូនជញ្ជូនចៅពួនដោយអគ្គីភ័យ ។ ឯព្រះបាទភជេសុររាជនៃលង្កាទ្វីប នៅតែមិនទាន់ព្រមចាញ់ ។ ព្រះបាទសុវណ្ណកុមារ ទ្រង់បានជ្រាបដោយប្រាជ្ញាញាណរបស់ព្រះអង្គថា សេនាបតីជាច្បងពីរនាក់របស់សីហឡទ្វីប នឹងក្បែយជន្មក្នុងរវាង ៧ ថ្ងៃទៀតទ្រង់នឹងថ្លែងសរសម្លាប់អគ្គសេនាបតីទាំងពីរនាក់" ។ ក្នុងថ្ងៃគំរប់ ៧ សេនាបតីជាច្បងទាំងពីរនាក់ ក៏អនិច្ចកម្មមែននៅក្នុងព្រះរាជមន្ទីរ ដែលគេបានចាត់ចែងការពារយ៉ាងម៉ឺងម៉ាត់ ។

ព្រះបាទភេជសុររាជ ទ្រង់បានឃើញភេទចម្លែកអស្ចារ្យដូច្នោះ ទ្រង់ព្រួយបារម្ភភិតភ័យតក្កមាយ៉ាងក្រៃលែង ទើបទ្រង់ជំនុំជាមួយនឹងអាមាត្យមុខមន្ត្រីទាំងឡាយថា "បើយើងនៅតែបបេសរឹងរូសតទៅទៀត មុខជាអាណាប្រជានុរាស្ត្រយើង នឹងខ្លួនយើងទាំងអស់គ្នានឹងស្លាប់អសារបង់ ដូច្នេះគួរយើងសុខចិត្តចុះចាញ់ សូមឲ្យមានជីវិតរស់នៅតទៅទៀត" ទើបស្តេចព្រមទាំងអាមាត្យមុខមន្ត្រីលើកភស្តុការបណ្ណាការចេញទៅ ក្រាបទូលថ្វាយព្រះបាទសុវណ្ណកុមារជាសញ្ញានៃការចុះចាញ់ ។

ព្រះបាទសុវណ្ណកុមារទ្រង់ត្រាស់ថា "បពិត្រមហារាជ សូមទ្រង់កុំភ័យ កុំព្រួយបារម្ភឲ្យសោះ ខ្ញុំគ្មានក្តីក្រោធខឹងនឹងទ្រង់ទេ ខ្ញុំមិនមែនមកដណ្តើមយករាជសម្បត្តិ នឹងដែនដីរបស់ទ្រង់ទេ គ្រាន់តែមកសូមយកដួងហឫទ័យរបស់ទ្រង់ប៉ុណ្ណោះ" ។

ព្រះបាទភជេសុររាជ បានទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏រឹងរឹតតែភិតភ័យញាប់ញ័ររន្ធត់ ត្រាតែព្រះសេទោហូរចេញស្រាក់ ។ ព្រះមហាក្សត្រទ្រង់បានទតឃើញដូច្នោះ ក៏មានព្រះហឫទ័យករុណាពន់ពេក ទើបត្រាស់លួងលោមថា "បពិត្រមហារាជ ខ្ញុំមិនមែនមកសុំយកសាច់បេះដូងរបស់ទ្រង់ទេ គឺគ្រាន់តែសូមឲ្យព្រះអង្គមានព្រះទ័យស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រ ចំពោះខ្ញុំហើយសូមឲ្យខ្ញុំមានមេត្រីរាប់អាន ចំពោះទ្រង់តែប៉ុណ្ណោះទេតើសូមទ្រង់ជ្រាប" ។ តអំពីនេះទៅ ព្រះមហាក្សត្រក្រុងពារាណសីទ្រង់បានព្រះរាជទានឱវាទផ្សេង ៗ ទៀតជាអនេកប្រការ សុទ្ធតែផ្អែកទៅលើកល្យាណធម៌នៃសប្បុរសទាំងអស់ ។ ព្រះបាទភជេសុររាជនៃសីហឡទ្វីប ទ្រង់មានព្រះទ័យរីករាយក្សេមក្សាន្តពន់ពេក ទើបស្តេចទូលតបថា "បពិត្រមហារាជ! សាធុ! សាធុ! ពិរោះណាស់ ព្រះឱង្ការរបស់ព្រះអង្គ សុទ្ធតែជាពាក្យសុភាសិតខ្ពង់ខ្ពស់ក្រៃលែង ខ្ញុំសូមថ្វាយជីវិត ដួងហឫទ័យនឹងសេចក្តីស្រឡាញ់ស្នេហា ព្រមទាំងរាជសម្បត្តិក្នុងដែនទាំងមូលចំពោះព្រះអង្គ សូមទ្រង់ទទួលយកតាមសព្វព្រះរាជហឫទ័យចុះ" ។

"បើដូច្នេះ សូមឲ្យទ្រង់ស្តេចយាងទៅនគរពារាណសីជាមួយនឹងខ្ញុំ ដើម្បីថ្វាយបង្គំ ព្រះវររាជបិតា-មាតាខ្ញុំ ក្នុងកាលឥឡូវនេះចុះ" ។

បពិត្រព្រះភូមិន្ទ សូមទ្រង់មេត្តារង់ចាំ ទំរាំខ្ញុំចាត់ចែងដំណើររួចស្រេចសិន" ។ ព្រះមហាសត្វ ក៏ទ្រង់យល់ព្រម ។

ព្រះបាទភជេសុររាជ ទ្រង់បានបង្គាប់អាមាត្រជាធំរបស់ទ្រង់ថា "ម្នាលអាមាត្រ ចូរអ្នករៀបកងទ័ពមានអង្គបួន ឲ្យបានគ្រប់គ្រាន់ ឲ្យពួកយោធាទាំងនោះ តែងកាយតាមថ្នាក់តាមជាន់តាមពួកក្រុមផ្សេង ៗ គ្នា ឲ្យស្លៀកពាក់ប្រដាប់ថ្មី ៗ អាវុធថ្មី ៗ គ្រប់គ្នា រួចហើយនាំគ្នាចូលទៅហែហមព្រះបាទសុវណ្ណកុមារជាមួយនឹងយើង" ។ ទ្រង់ឲ្យចាត់ចែងរៀបចំដំណើរអស់កំឡុង ១ ខែទើបស្រេច ។ ព្រះបាទសុវណ្ណកុមារទ្រង់ឡើងគង់ដំរីរ័ត្នមង្គល ស្តេចបរពេលដរាបដល់មហាសមុទ្រ ដោយរីករាយក្សេមក្សាន្ត ទ្រង់ឲ្យកងទ័ពសំចតនៅឆ្នេរសមុទ្រអស់កម្លុង ៧ ថ្ងៃ បើកដៃឲ្យពួកពលសកលយោធាលេងល្បែងមហាស្រពផ្សេង ៗ តាមចំណង់ ។

លុះបានឫក្សពារពេលល្អ ព្រះរាជាទ្រង់នាំពួកពលសេនាយោធាចុះកាន់រាជនាវាដ៏រុងរឿង ព្រះបាទសីហឡទ្វីប នឹងពួកយោធាទាំងពួង ក៏នាំគ្នាស្រែកថ្វាយពរជ័យបីដង ហើយនាំគ្នាត្រូសងចុះកាន់នាវាតែរៀង ៗ ខ្លួន ។ ពួកសមុទ្ទទេវតានឹងស្តេចនាគទាំងឡាយ ក៏នាំគ្នានិមិត្តប្រាសាទរ័ត្នថ្វាយព្រះមហា-ក្សត្រ នៅលើសុវណ្ណនាវា ហើយបានចាត់ការថែរក្សាមហានាវាទាំងអស់ពុំឲ្យមានក្តីអន្តរាយ ។ មារុតទេវតាទាំងឡាយ ក៏បញ្ចេញវាយោបក់រំភើយ ៗ រហើយស្រួលសព្វកាយា បក់សំពៅភេត្រាឲ្យល្បឿនយលដោយស្រួលលើផ្ទៃនៃមហាសមុទ្រ ។ សមុទ្ទទេវតានាំយកភោជនាហារ មានឱជារសថ្លៃថ្លាមកថ្វាយព្រះមហាសត្វ ព្រមទាំងពួកពល ។ ពួកនាងសមុទ្ទកញ្ញានាំគ្នា

តែងកាយយ៉ាងស្រស់ថ្លៃថ្លា ដៃកាន់ទិព្វមាលាបុប្ផាបូជាព្រះនរបតីរាល់ទិវារាត្រី ។ ជនទាំងអស់ក្នុងនាវាទាំងឡាយ តែងខ្លួនយ៉ាងស្អាត ច្រៀងរាំសើចសប្បាយ ទះដៃលេងយ៉ាងខ្ញៀវខ្ញារគគ្រឹកគគ្រេងរាល់ ៗ ថ្ងៃ ត្រាតែដល់ទៅឆ្នេរសមុទ្រនៃនគរពារាណសី ។

ឯព្រះវររាជមាតា-បិតាទ្រង់បានឲ្យបាត់បែងមាគ៌ា ពីក្រុងពារាណសីដរាបដល់ឆ្នេរសមុទ្រ ទើបស្ដេចព្រមដោយអាមាត្រមុខមន្ត្រីនឹងរាជបរិវារផង ស្ដេចចេញទៅទទួលព្រះរាជបុត្រដង្ហែចូលមកស្រុងពារាណសី ។ ព្រះបាទសុវណ្ណកុមារបានថ្វាយភស្តុការបណ្ណាការដ៏មានតម្លៃផ្សេង ៗ ព្រមទាំងស្ដេចភជេសុររាជនឹងពួកពលយោធា ។ ព្រះវរមាតា-បិតាទ្រង់អបអរសាទរនឹងព្រះរាជបុត្រណាស់ ទ្រង់បានប្រទានស័ព្ទសាធុការពរផ្សេង ៗ ។ តមកព្រះបាទសុវណ្ណកុមារទ្រង់អនុញ្ញាតឲ្យស្ដេចភជេសុររាជ ព្រមទាំងពួកពលត្រឡប់ទៅគ្រងរាជ្យនៅនគររបស់ទ្រង់វិញ ។ ព្រះមហាក្សត្រទ្រង់គ្រប់គ្រងរាជ្យដោយធម៌ រាស្ត្រប្រជាប្រកបដោយក្ដីក្សេមក្សាន្ត ។ ព្រះនរបតីទ្រង់បានបំពេញកុសលផ្សេងៗមានទានសីលជាដើមដរាបដល់អស់ព្រះជន្មាយុ៕

---

# លិខិតគាំទ្រ

## របស់សហព័ន្ធខ្មែរកម្ពុជាក្រោម ចំពោះព្រឹត្តបត្រ BMD របស់ព្រះមហាក្សត្រ ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ

សហព័ន្ធខ្មែរកម្ពុជាក្រោម និងប្រជាពលរដ្ឋខ្មែរក្រោមទូទាំងពិភពលោក សូមសម្ដែងនូវការគាំទ្រយ៉ាងខ្លាំងទៅលើការធ្វើសេចក្ដីបញ្ជាក់តាមព្រឹត្តិបត្រ BMD របស់ព្រះមហាវរក្សត្រ ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ ពីទីក្រុងប៉េកាំង ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៥ ។

សេចក្ដីបញ្ជាក់ទាំងបីចំណុចបានបង្ហាញយ៉ាងច្បាស់ថា ខ្មែរក្រោមជាម្ចាស់ដើមនៃដែនដីកម្ពុជាក្រោម ។ ការប្រគល់ដោយខុសច្បាប់របស់បារាំងគឺរំលោភលើសិទ្ធិខ្មែរក្រោមទាំងស្រុង ។ ជាពិសេស ប្រមាថមើលងាយព្រះរាជាណាចក្រកម្ពុជា និង ប្រជាពលរដ្ឋខ្មែរទាំងមូល ។

ខ្មែរក្រោមជាប្រជាពលរដ្ឋខ្មែរ ដែលត្រូវទទួលរងគ្រោះពីអាណានិគមមួយទៅមួយទៀត ពីសង្គ្រាមមួយទៅសង្គ្រាមមួយទៀត រហូតមកទល់បច្ចុប្បន្ននេះ ។

ទូលព្រះបង្គំដែលជាកូនចៅខ្មែរក្រោម មានចិត្តរំភើបរីករាយជាអនេកកប្បការ និងដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះមហាវរក្សត្រ ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ ដែលបានបកស្រាយយ៉ាងច្បាស់ ឲ្យកូនចៅបានឃើញនូវភាពពិតនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងពីភាពអយុត្តិធម៌ដែលខ្មែរក្រោមរងគ្រោះ ក៏ដូចជាប្រជា–ពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា ៕

ប្រទេសកាណាដា, ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៥

ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម

*ថាច់ ង៉ុកថាច់*